ក

មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

១-ព្រះរាជក្រម

០៨-០២-២០០៧ -ព្រះរាជក្រម នស/រកម/០២០៧/០០៩ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី ៣ របស់អាស៊ានស្តីពីប្រភេទ និងបរិមាណយានយន្តផ្លូវគោក ២០៩២

២-ព្រះរាជក្រឹត្យ

១២-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៦០ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ជូនឯកឧត្តម លោកជំទាវ និង អស់លោក ចំនួន ១១ រូប ២១១៧

១៦-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៦៧ ស្តីពីការតាំងស៊ុបក្នុងក្របខ័ណ្ឌនៃអង្គចៅក្រម ចំពោះលោក លោកស្រី ចៅក្រម-ព្រះរាជអាជ្ញារង កម្មសិក្សា ជាចៅក្រម ជាព្រះរាជអាជ្ញារង និងត្រូវចាត់ឱ្យទៅបំរើការងារ នៅតាមអង្គភាព និងសាលាជំរះក្តីនានា ២១១៨

១៦-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៦៨ ស្តីពីការតែងតាំងមន្ត្រីតុលាការ ២១២៣

១៦-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៦៩ ស្តីពីការផ្ទេរភារកិច្ចមន្ត្រីតុលាការ ២១២៣

១៦-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៧០ ស្តីពីការអនុញ្ញាតឱ្យមន្ត្រីតុលាការ ០២រូប ចូលបំរើការងារវិញ ២១២៨

១៦-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៧១ ស្តីពីការអនុញ្ញាតជូនចៅក្រម និង ព្រះរាជអាជ្ញា ដែលដល់អាយុចូលនិវត្តន៍ ឱ្យនៅបន្តបំរើការងារមួយរយៈ ២១២៩

១៦-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៧២ ស្តីពីការដាក់ឱ្យចូលនិវត្តន៍ ចៅក្រម ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារង គិតចាប់ពីខែតុលា ឆ្នាំ ២០០៥ តទៅ ២១៣១

១៦-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៧៣ ស្តីពីការដាក់វិន័យលោក **នង សុខ** អនុប្រធានតុលាការខេត្តរតនគិរី ក្រោមរូបភាព ដាក់ឱ្យចូលនិវត្តន៍ មុនកាលកំណត់ ២១៣៣

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

២២-០២-២០០៧ -អនុក្រឹត្យលេខ ១៣ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២១៣៤
២៦-០២-២០០៧ -អនុក្រឹត្យលេខ ១៦៧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២១៤៧
២៦-០២-២០០៧ -អនុក្រឹត្យលេខ ១៦៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២១៤៨
២៦-០២-២០០៧ -អនុក្រឹត្យលេខ ១៦៩ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២១៥០
២៦-០២-២០០៧ -អនុក្រឹត្យលេខ ១៧០ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២១៥១
២៦-០២-២០០៧ -អនុក្រឹត្យលេខ ១៧១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១៥៣
២៦-០២-២០០៧ -អនុក្រឹត្យលេខ ១៧២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១៥៥
២៦-០២-២០០៧ -អនុក្រឹត្យលេខ ១៧៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១៥៦
២៦-០២-២០០៧ -អនុក្រឹត្យលេខ ១៧៤ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២១៥៧
២៦-០២-២០០៧ -អនុក្រឹត្យលេខ ១៧៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២១៥៩

២. សេចក្តីសំរេច

២៣-០២-២០០៧ -សេចក្តីសំរេចលេខ ០៨ សសរ ស្តីពីការរៀបចំ " វេទិកាសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី ១ " ២១៦០
២៣-០២-២០០៧ -សេចក្តីសំរេចលេខ ០៩ សសរ ស្តីពី " ឯកសារណែនាំសំរាប់ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមការងារបច្ចេកទេសចំរុះ " ២១៦២

III. ការងារបណ្តាក្រសួង

១. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២៦-០២-២០០៧ -ប្រកាសលេខ ២៥៤ ឧរថ.បល.ប្រក ស្តីពីការបង្កើតការិយាល័យស្ថិតិ និងព័ត៌មានវិទ្យាចំណុះនាយកដ្ឋានឧស្សាហកម្មតូច និងសិប្បកម្ម ២១៦៤

២. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៤-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៩៧៩ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី & ខេស៊ី** ២១៦៧

គ

២៤-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៩៨០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គ្លូប៊ល ហើរេធច ធូរ** ២១៦៩

២៤-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៩៨២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីង ខេម អេនជីនារីង** ២១៧១

២៤-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៩៨៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភ្នំពេញ ហាន់នីប្រូដាក់ (ខេមបូឌា)** ២១៧៣

២៤-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៩៨៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គីម ឌុក ស៊ូ អ៊ិនធើណេសិនណល** ២១៧៥

២៤-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៩៨៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថប ហ្វេមើស អ៊ិនដាសស្ទ្រី លីមីធីត** ២១៧៧

២៤-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៩៩០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម មិង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី ទ៉ាយ ស៊ី** ២១៧៩

២៤-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៩៩១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វូនីក ឃ្លារេនស៍ (ខេមបូឌា) លីមីធីត** ២១៨១

២៤-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៩៩២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡាក់ឃី ឌីវេឡុបមេន ខូ អិលធីឌី** ២១៨៣

២៤-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៩៩៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **(ខេមបូឌា) វីស៊ីថ ម៉ាញនីង ឌីវេឡុបមេន** ២១៨៥

២៧-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៩៩៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អង្គរ ក្រោន សេនធ័រ** ២១៨៧

២៧-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៩៩៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អា អា សេ ជេ** ២១៨៩

២៧-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៩៩៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លីនតុន ទើរ៉ែល (ខេមបូឌា)** ២១៩១

២៧-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៩៩៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមខូ អ៊ែសិត មេនេចមេន អិលធីឌី** ២១៩៣

២៧-១១-២០០៦ -លិខិតបញ្ជាក់លេខ ៣០០២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាវ៉ាទុង ត្រេឌីង ខូ អិលធីឌី** ២១៩៤

២៧-១១-២០០៦ -លិខិតបញ្ជាក់លេខ ៣០០៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភ្នំពេញ មេឌីខល ស៊ីទីស ខមភេនី លីមីធីត** ២១៩៦

២៧-១១-២០០៦ -លិខិតបញ្ជាក់លេខ ៣០០៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួល ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភ្នំពេញ ហ្វ៊ីស ប្រូឌីធ ខមភេនី លីមីធីត** ២១៩៧

២៧-១១-២០០៦ -លិខិតបញ្ជាក់លេខ ៣០០៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូឌា ប្រូជេក ផ្លេនីង & ឌីវេឡុបមេន មេនេចមេន (ស៊ីភីភីឌីអឹម)** ២១៩៨

២៨-១១-២០០៦ -លិខិតបញ្ជាក់លេខ ៣០០៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដាប់ប៊ែល យូ អិលធី (ខេមបូឌា)** ២២០០

២៨-១១-២០០៦ -លិខិតបញ្ជាក់លេខ ៣០០៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ត្រូសលីង ថេក (ខេមបូឌា)** ២២០២

២៨-១១-២០០៦ -លិខិតបញ្ជាក់លេខ ៣០១០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្តារហ្វ៊ីល អិលធីឌី** ២២០៤

២៨-១១-២០០៦ -លិខិតបញ្ជាក់លេខ ៣០១២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភ្នំពេញ-សេអ៊ីល ហ្វ្រេនស៊ីប ឌីវេឡុបមេន** ២២០៦

២៩-១១-២០០៦ -លិខិតបញ្ជាក់លេខ ៣០១៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អូតូម៉ាញ ខូ អិលធីឌី** ២២០៨

២៩-១១-២០០៦ -លិខិតបញ្ជាក់លេខ ៣០២៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីដ អេនជីនារីង** ២២១០

២៩-១១-២០០៦ -លិខិតបញ្ជាក់លេខ ៣០២៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធីរះ ម៉ិនថាំ អេចប្រេស** ២២១២

២៩-១១-២០០៦ -លិខិតបញ្ជាក់លេខ ៣០២៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជី-មូ** ២២១៤

២៩-១១-២០០៦ -លិខិតបញ្ជាក់លេខ ៣០២៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វើលវ៉ាយដ៍ អ៊ិនវេសមេន អ៊ិនខបភើរេសិន** ២២១៦

៣០-១១-២០០៦ -លិខិតបញ្ជាក់លេខ ៣០២៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឆាច សេច អ៊ិនវេសមេន ឌីវេឡុបមេន លីមីធីត ខមភេនី** ២២១៨

៣០-១១-២០០៦ -លិខិតបញ្ជាក់លេខ ៣០៣៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មីសែល ខបភើរេសិន** ២២២០

៣០-១១-២០០៦ -លិខិតបញ្ជាក់លេខ ៣០៣៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផលចំរើន ស្ហ្គី ខូ អិលធីឌី** ២២២២

០១-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣០៥៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តៃនីញ អំពង់ធំ អភិវឌ្ឍន៍ គៅស៊ូ** ២២២៤

ព្រះរាជក្រម

នស/រកម/០២០៧/០០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៣ របស់អាស៊ានស្តីពីប្រភេទ និងបរិមាណយានយន្តផ្លូវគោក ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី២ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

/3 w

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើពិធីសារទី ៣ របស់ អាស៊ានស្តីពីប្រភេទ និងបរិមាណយានយន្តផ្លូវគោក

មាត្រា ១.-

អនុម័តយល់ព្រមលើពិធីសារទី ៣ របស់អាស៊ានស្តីពីប្រភេទ និងបរិមាណយានយន្តផ្លូវគោក ដែលធ្វើនៅទីក្រុងហាណូយ ប្រទេសវៀតណាម នាថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ២០០៧

ពរ/ល.០៧០២.០៦៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ហត្ថលេខា

ស៊ុន ចាន់ថុល

លេខ: ៩២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ... ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

ពិធីសារអាស៊ាន

ពិធីសារទី ៣

ស្តីពី

ប្រភេទ និងបរិមាណយានយន្តផ្លូវគោក

TYPES AND QUANTITY OF ROAD VEHICLES

នាយកដ្ឋានផែនការ - មិថុនា ២០០២

PLANNING DEPARTMENT, JUNE 2002

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

ៈ...៨៥...អនក្រ.កបច

សេចក្តីថ្លែងហេតុនៃ
សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រម លើពិធីសារអាស៊ាន
ស្តីពីប្រភេទ និងបរិមាណយានយន្តផ្លូវគោក

ក- លំនាំដើម

នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំលើកទី ៥ របស់រដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន ដែលប្រព្រឹត្តទៅនៅថ្ងៃទី ១៤-១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម រដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ានបានឯកភាពយល់ព្រម និងចុះហត្ថលេខា លើពិធីសារ និងកិច្ចព្រមព្រៀងចំនួន ៣ ដូចខាងក្រោម :

- ពិធីសារទី ៣ : ស្តីពីការកំណត់ប្រភេទ និងបរិមាណយានយន្តដឹកជញ្ជូនផ្លូវគោក
- ពិធីសារទី ៤ : ស្តីពីតម្រូវការបច្ចេកទេសរបស់យានយន្ត
- កិច្ចព្រមព្រៀងថ្នាក់រដ្ឋមន្ត្រីស្តីពីការអភិវឌ្ឍបណ្តាញផ្លូវអាស៊ានហាយវេ

ពិធីសារទី ៣ គឺជាពិធីសារលំអិតផ្នែកបច្ចេកទេស សម្រាប់អនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសម្រួលក្នុងការដឹកជញ្ជូនទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខានាខែ សីហា ឆ្នាំ ១៩៩៨ នៅទីក្រុងហាណូយ ប្រទេស វៀតណាម ដែលជាកិច្ចព្រមព្រៀងមួយនៅក្នុងចំណោមកិច្ចព្រមព្រៀង និងពិធីសារទាំង ២៧ របស់អាស៊ាន ហើយដែលសភាជាតិបានផ្តល់សច្ចាប័នទទួលស្គាល់រួចហើយកាលពីឆ្នាំ ២០០០ កន្លងទៅ បន្ទាប់ពីកម្ពុជាបានចូលជាសមាជិកអាស៊ាន។ កិច្ចព្រមព្រៀងនេះតម្រូវឱ្យប្រទេសជាសមាជិកយល់ព្រម និងចុះហត្ថលេខាលើពិធីសារចំនួន៩ ដែលលំអិតខាងបច្ចេកទេសសម្រាប់អនុវត្តកិច្ចព្រមព្រៀង :

ពិធីសារទី១:ការកំណត់ទុកជាមុននៃផ្លូវនិងមធ្យោបាយលើផ្លូវផ្តល់សម្រាប់សម្រួលក្នុងការដឹកជញ្ជូនឆ្លងកាត់

ពិធីសារទី ២ : ការកំណត់ជាមុននៃប៉ុស្តិ៍ត្រួតពិនិត្យតាមព្រំដែន

ពិធីសារទី ៣ :ប្រភេទ និងបរិមាណនៃយានយន្តតាមផ្លូវគោក

ពិធីសារទី ៤ : តម្រូវការខាងបច្ចេកទេសនៃយានយន្ត

ពិធីសារទី ៥ : ផែនការអាស៊ាននៃការធានារ៉ាប់រងក្នុងកាតព្វកិច្ចទទួលខុសត្រូវរបស់យានយន្ត

ពិធីសារទី ៦ : ព្រំដែនផ្លូវដែក និងស្ថានីយបំបែកផ្លូវដែកទាំងឡាយ

ពិធីសារទី ៧ : ប្រព័ន្ធគយសម្រាប់ការឆ្លងកាត់

ពិធីសារទី ៨ : វិធានការអនាម័យ និងភូតគាមអនាម័យ

ពិធីសារទី ៩ : ទំនិញគ្រោះថ្នាក់

មានពិធីសារចំនួន ៣ ដែលបានចុះហត្ថលេខារួចហើយដោយរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន :

ពិធីសារទី ៣ : ប្រភេទ និងបរិមាណនៃយានយន្តតាមផ្លូវគោក (ចុះហត្ថលេខានៅឆ្នាំ ១៩៩៩)

ពិធីសារទី ៤ : តម្រូវការខាងបច្ចេកទេសនៃយានយន្ត (ចុះហត្ថលេខានៅឆ្នាំ ១៩៩៩)

ពិធីសារទី ៩ : ទំនិញគ្រោះថ្នាក់ (ចុះហត្ថលេខាកាលពីឆ្នាំ ២០០២ និងកំពុងសុំសច្ចាប័នពីរដ្ឋសភាជាតិ)

មានពិធីសារចំនួន ០២ ទៀតបានចុះហត្ថលេខានៅចុងឆ្នាំ ២០០០ និងដើមឆ្នាំ ២០០១
ដោយក្រសួង ស្ថាប័នផ្សេងៗ :

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ពិធីសារទី ៥ : ផែនការអាស៊ាននៃការធានារ៉ាប់រងក្នុងកាតព្វកិច្ចទទួលខុសត្រូវរបស់យានយន្ត (ពិធីសារនេះ បានផ្តល់សច្ចាប័នរួចហើយពីរដ្ឋសភាជាតិកាលពីឆ្នាំ ២០០២ កន្លងទៅ)

ក្រសួងកសិកម្ម និងក្រសួងសុខាភិបាល

- ពិធីសារទី ៨ : វិធានការអនាម័យ និងភូតគាមអនាម័យ (ពិធីសារនេះ បានផ្តល់សច្ចាប័នរួចហើយពីរដ្ឋសភាជាតិកាលពីឆ្នាំ ២០០២ កន្លងទៅ)

មានពិធីសារ ៤ ទៀតដែលពុំទាន់បានចុះហត្ថលេខា :

-ពិធីសារទី១ : ការកំណត់ទុកជាមុនផ្លូវ និងមធ្យោបាយលើផ្លូវផ្តល់សម្រាប់សម្រួលក្នុងការដឹកជញ្ជូនឆ្លងកាត់ ។ បច្ចុប្បន្នពិធីសារនេះបានឈានចូលដល់ដំណាក់កាលឯកភាពគ្នា នឹងចុះហត្ថលេខានៅខែ វិច្ឆិកា ឆ្នាំ ២០០៥ ក្នុងឱកាសនៃកិច្ចប្រជុំរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ានលើកទី ១១ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ។

- ពិធីសារទី ៦ : ព្រំដែនផ្លូវដែក និងស្ថានីយបំបែកផ្លូវដែកទាំងឡាយ (ពិធីសារនេះនៅរង់ចាំចម្លើយជាចុងក្រោយពីប្រទេសសិង្ហបុរី និងអាចចុះហត្ថលេខាបាននៅឆ្នាំ ២០០៦ ខាងមុខ) រាជរដ្ឋាភិបាលបានផ្តល់សិទ្ធិ

ប្រទានរួចហើយជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីចុះហត្ថលេខាកាលពីឆ្នាំ ២០០១ និង ២០០៤ កន្លងទៅ ។

- ពិធីសារ ២ : ការកំណត់ជាមុននៃប៉ុស្តិ៍តាមព្រំដែន
- ពិធីសារ ៧ : ប្រព័ន្ធគយសម្រាប់ការឆ្លងកាត់

ពិធីសារទាំង ២ នេះ ជាសមត្ថកិច្ចរបស់ស្ថាប័នគយ ដែលត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន ប៉ុន្តែត្រូវជាប់គាំងដោយពិធីសារទី១ : (ការកំណត់ទុកជាមុននៃផ្លូវ និងមធ្យោបាយលើផ្លូវផ្តល់សម្រាប់សម្រួលក្នុងការដឹកជញ្ជូនឆ្លងកាត់) ដែលពុំទាន់អាចចុះហត្ថលេខាបាន ។

ពិធីសារទី ៣ មាន ៨ មាត្រា និងឧបសម្ព័ន្ធ ១ ដែលបានចុះហត្ថលេខានៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម ដោយរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន ។

គោលបំណង នៃពិធីសារទី ៣ គឺដើម្បីកំណត់ប្រភេទ និង បរិមាណយានយន្ត សម្រាប់អនុវត្តក្នុងការសម្រួលការដឹកជញ្ជូនទំនិញឆ្លងកាត់ កំណត់កាតព្វកិច្ច និងការរៀបចំស្ថាប័នរបស់ភាគីចុះកិច្ចសន្យា ឬប្រទេសជាសមាជិក និងការចូលរួមរបស់ប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់ ។

I- ខ្លឹមសារសង្ខេប និងចំណុចសំខាន់ៗ

- ពិធីសារបានកំណត់និយមន័យ ប្រភេទ និងវិសាលភាព នៃការអនុវត្តទៅលើគ្រប់យានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវផ្តល់ និងប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់។ ភាគីទាំងឡាយយល់ព្រមថា ប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់អាចអនុញ្ញាតឱ្យប្រើប្រាស់យានយន្តទៅតាមប្រភេទ និងបរិមាណដូចបានកំណត់ក្នុងពិធីសារ និងឧបសម្ព័ន្ធរបស់វា។ ជាជំហានដំបូងបរិមាណយានយន្តចំនួន៦០គ្រឿងសម្រាប់ភាគីនិមួយៗ ត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ ហើយបរិមាណនេះត្រូវលើកយកមកពិភាក្សា កែប្រែជាបន្តបន្ទាប់ដោយភាគីទាំងអស់
- ភាគីទាំងអស់យល់ព្រមឱ្យយានយន្តដឹកជញ្ជូនឆ្លងកាត់ ចេញ-ចូល និងចល័តដោយសេរី នៅលើផ្លូវដែលបានកំណត់ក្នុងពិធីសារទី១។ យានយន្តដឹកជញ្ជូនឆ្លងកាត់របស់ភាគីនិមួយៗ ដែលធ្វើប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ទឹកដីភាគីដទៃត្រូវគោរព និងអនុវត្តទៅតាមបទប្បញ្ញត្តិទាំងឡាយ នៃការដឹកជញ្ជូនតាមផ្លូវផ្តល់ នៃភាគីនោះ ។ យានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវផ្តល់ទាំងនោះ ត្រូវបំពេញទៅតាមតម្រូវការខាងបច្ចេកទេសត្រឹមត្រូវដូចកំណត់ក្នុងពិធីសារទី ៣ ទើបអាចធ្វើប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់បាន

-កិច្ចប្រជុំមន្ត្រីដឹកជញ្ជូនជាន់ខ្ពស់ គឺជាអ្នកទទួលខុសត្រូវសម្របសម្រួល ត្រួតពិនិត្យ និងធ្វើរបាយការណ៍ទៀងទាត់ អំពីភាពជឿនលឿនក្នុងការអនុវត្តពិធីសារនេះ ជូនក្រុមប្រឹក្សាសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ថ្នាក់តំបន់របស់អាស៊ាន ដោយមានការជួយទ្រទ្រង់ខាងបច្ចេកទេស និងតាមរយៈលេខាធិការដ្ឋានអាស៊ាន

-ពិធីសារនេះត្រូវបានគេចុះហត្ថលេខា និងតម្កល់ទុកនៅលេខាធិការដ្ឋានអាស៊ាន ដែលជាអ្នកចែកផ្សព្វផ្សាយឱ្យបានរហ័សទៅគ្រប់ភាគី

- ពិធីសារនេះ និងឧបសម្ព័ន្ធរបស់វា គឺជាផ្នែកបញ្ចូលគ្នា ជាមួយកិច្ចព្រមព្រៀង

- ពិធីសារនេះ ជាកម្មវត្ថុនៃការធ្វើសច្ចាប័ន ឬ ការយល់ព្រមដោយភាគីចុះកិច្ចសន្យា

-លិខិតុបករណ៍នៃការធ្វើសច្ចាប័ន ឬការចូលត្រូវតម្កល់នៅលេខាធិការដ្ឋានអាស៊ាន ដែលជាអ្នកផ្សព្វផ្សាយយ៉ាងរហ័សទៅភាគីចុះកិច្ចសន្យា

-ពិធីសារចូលជាធរមាននៅពេលលិខិតុបករណ៍នៃការធ្វើសច្ចាប័ន ឬការចូលពីគ្រប់ភាគីបានតម្កល់ទុកនៅលេខាធិ-ការដ្ឋានអាស៊ាន

- វិសោធនកម្មនៃពិធីសារ និងឧបសម្ព័ន្ធរបស់វាអាចប្រព្រឹត្តទៅបាន តាមការព្រមព្រៀងពីគ្រប់ភាគីទាំងអស់ ។

អាស្រ័យដូចបានទូលថ្វាយ និងជម្រាបជូនខាងលើនេះ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារអាស៊ាន ស្តីពីប្រភេទ និងបរិមាណយានយន្តផ្លូវគោកនេះ ដោយអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

ពិធីសារទី ៣
ប្រភេទ និងបរិមាណយានយន្តផ្លូវគោក

❖❖❖❖❖✿❖❖❖❖❖

រដ្ឋាភិបាល នៃប្រទេស ប្រ៊ុយណេ ដារូសាឡាម, ព្រះរាជាណាចក្រកម្ពុជា, សាធារណរដ្ឋឥណ្ឌូណេស៊ី, សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ, ប្រទេសម៉ាឡេស៊ី, សាធារណរដ្ឋហ្វីលីពីន, សាធារណរដ្ឋសិង្ហបុរី, ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម, គឺជារដ្ឋសមាជិក នៃសមាគមប្រជាជាតិ អាស៊ីភាគអាគ្នេយ៍ (ពីពេលនេះតទៅ ហៅកាត់ថា " ភាគីចុះកិច្ចសន្យា ")

រំលឹកឡើងវិញ កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសំរបសំរួលទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខា នៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៩៨ នៅទីក្រុងហាណូយ ប្រទេសវៀតណាម (ពីពេលនេះតទៅហៅកាត់ថា " កិច្ចព្រមព្រៀង ")

កត់សំគាល់ ថាមាត្រា ៩ និង ២៥ នៃកិច្ចព្រមព្រៀងនោះ ផ្តល់អោយសំរាប់ការសំរេចនូវការអនុវត្តន៍ពិធីសារ ដែលនឹងបង្កើតទៅជាផ្នែករួមបញ្ចូលគ្នា ជាមួយកិច្ចព្រមព្រៀង ។

រំលឹកឡើងវិញបន្ថែម នូវផែនការសកម្មភាព ទីក្រុងហាណូយ ដែលបានយល់ព្រមដោយបណ្តាប្រមុខរដ្ឋ និងរដ្ឋាភិបាលអាស៊ាន នៅឯកិច្ចប្រជុំកំពូលអាស៊ានលើកទី ៦ នៅទីក្រុងហាណូយ ប្រទេសវៀតណាម នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៨ ដែលចែងអោយធ្វើការប្រតិបត្តិ កិច្ចព្រមព្រៀងនៅឆ្នាំ ២០០០ ។

បច្ចុប្បន្នដោយហេតុដូចនោះ បណ្តាភាគីចុះកិច្ចសន្យា បានព្រមព្រៀងគ្នាដូចខាងក្រោម :

មាត្រាទី ១
និយមន័យ

សំរាប់បំរើអោយគោលបំណងនៃពិធីសារនេះ

ក- " ប្រតិបត្តិករ ដឹកជញ្ជូនឆ្លងកាត់ " មានន័យថា បណ្តាម្ចាស់កម្មសិទ្ធរថយន្ត អ្នកបើកបរ និង / ឬ ក៏បណ្តាភ្នាក់ងារទាំងឡាយនៃយានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោក ដែលជាអ្នកមានការអនុញ្ញាត ឬមានអាជ្ញាប័ណ្ណអនុញ្ញាតថ្នាក់ជាតិ យ៉ាងសមរម្យ ដើម្បីប្រតិបត្តិនូវសេវាដឹកជញ្ជូន និងជាអ្នកដែលបានចុះបញ្ជី ក្នុងការអនុវត្តន៍ ស្របទៅតាមបទប្បញ្ញត្តិ និងនិតិវិធី នៅក្រោមការអនុញ្ញាត ឬអាជ្ញាប័ណ្ណអនុញ្ញាត ដែលបាននិយាយខាងលើ និងដែលបានចុះបញ្ជី យ៉ាងត្រឹមត្រូវថាជា " ប្រតិបត្តិករដឹក

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

ជញ្ជូនឆ្លងកាត់ " ជាមួយនឹង គណៈកម្មការជាតិ សំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ (គជសដឆ) របស់ពួកគេទាំងឡាយរៀង១ខ្លួន ។

ខ- " យានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោក " មានន័យថា ជាប្រភេទនៃយានយន្តលើផ្លូវគោកទាំងឡាយដែលបានបញ្ជាក់ ក្នុងមាត្រាទី ៣ នៅទីនេះសំរាប់ការប្រើប្រាស់ក្នុងការដឹកទំនិញឆ្លងកាត់ដែនដីនៃភាគីចុះកិច្ចសន្យាមួយ ឬច្រើន នៅពេលដែលការធ្វើដំណើរឆ្លងកាត់នោះធ្វើឡើងកាត់តាមដែនដី ឬដែនដីទាំងឡាយដូចខាងលើនេះ ដោយមានជាប់ជាមួយ ឬមិនមានជាប់ជាមួយ នូវបន្ទុកទំនិញ ការស្តុកទំនិញបណ្តោះអាសន្ន នៅកន្លែងទុកដាក់ណាមួយ ការបំបែកទំនិញជាដុំ១ដាច់ពីគ្នា ឬក៏ការផ្លាស់ប្តូរប្រភេទ នៃការដឹកជញ្ជូន គឺគ្រាន់តែជាចំណែកមួយ នៃការធ្វើដំណើរមួយចប់ផ្លូវ ដោយចាប់ផ្តើម និងបញ្ចប់ ទៅហួស ឬនៅក្រៅវង្វង់ព្រំដែន នៃភាគីចុះកិច្ចសន្យាមួយ ឬច្រើន ដែលចរាចរឆ្លងកាត់ធ្វើឡើងកាត់តាមដែនដី នៃភាគីនោះ ។

គ- " ការដឹកជញ្ជូនឆ្លងកាត់ " ត្រូវមានអត្ថន័យដូចបានកំណត់អោយវានៅក្នុងកិច្ចព្រមព្រៀង ។

ឃ- " ពិធីសារទី៤ " មានន័យថាពិធីសារទី ៤ ស្តីពី តម្រូវការបច្ចេកទេសយានយន្ត ដោយអនុលោមទៅតាមកិច្ចព្រមព្រៀង ។

មាត្រាទី ២
ទំហំនៃការអនុវត្តន៍

១- អនុលោមទៅតាមប្រការ ៩.២ នៃ " កិច្ចព្រមព្រៀង" ភាគីចុះកិច្ចសន្យាទាំងឡាយ តាមរយៈនេះយល់ព្រមធ្វើតាមបញ្ញត្តិទាំងឡាយ នៃពិធីសារនេះ ទៅលើយានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោកមួយ ដែលចូលរួមក្នុងការដឹកជញ្ជូនឆ្លងកាត់ ។

២- ពិធីសារនេះត្រូវអនុវត្តទៅលើគ្រប់បណ្តាយានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោក និងអ្នកប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់ដូចដែលបានកំណត់ក្នុងមាត្រា ១ នៃពិធីសារនេះ ។

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

មាត្រា ៣
ប្រភេទទាំងឡាយ នៃយានយន្ត

ភាគីចុះកិច្ចសន្យាទាំងឡាយតាមរយៈនេះយល់ព្រមថា អ្នកធ្វើប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់និមួយៗ មិនត្រូវបានគេអនុញ្ញាត អោយចូលរួមក្នុងការដឹកជញ្ជូនឆ្លងកាត់ ដោយប្រើប្រាស់យានយន្តតាមផ្លូវគោកទាំងឡាយផ្សេងៗទៀត ក្រៅអំពីយានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោកដែលបានកំណត់ នៅក្នុងឧបសម្ព័ន្ធ ១ ។

មាត្រា ៤
បរិមាណ

អនុលោមទៅតាមមាត្រាទី៩.២ នៃកិច្ចព្រមព្រៀង ភាគីចុះកិច្ចសន្យាទាំងឡាយតាមរយៈនេះយល់ព្រមថា បរិមាណនៃយានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោកទាំងឡាយ ដែលត្រូវបានគេអនុញ្ញាត ដើម្បីអោយប្រើប្រាស់ក្នុងការដឹកជញ្ជូនឆ្លងកាត់ ត្រូវមានបរិមាណយានយន្ត ហុកសិប (៦០) សំរាប់ភាគីចុះកិច្ចសន្យា និមួយៗ ។ ជាបន្តបន្ទាប់មកទៀត បរិមាណនៃយានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោក នឹងត្រូវលើកយកមកពិភាក្សាគ្នា ពីមួយពេលទៅមួយពេល រវាងបណ្តាភាគីចុះកិច្ចសន្យាទាំងឡាយ ។

មាត្រា ៥
ភាតព្វកិច្ច

១- យោងតាមមាត្រាទី ២៤ នៃកិច្ចព្រមព្រៀង ភាគីចុះកិច្ចសន្យាទាំងឡាយតាមរយៈនេះយល់ព្រមអនុញ្ញាតអោយមានការចេញ-ចូល និងចល័តដោយពុំមានការរារាំង នូវយានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោក នៅលើផ្លូវដឹកជញ្ជូនឆ្លងកាត់ដែលបានកំណត់ ។

២- ភាគីចុះកិច្ចសន្យាទាំងឡាយត្រូវប្រកាន់យកនូវវិធានការសមស្របនានា ដើម្បីធានាថាបណ្តាយានយន្តដឹកជញ្ជូនឆ្លងកាត់ទាំងឡាយរបស់ពួកគេរៀងៗខ្លួន អនុវត្តតាមបទប្បញ្ញត្តិទាំងឡាយ នៃការដឹកជញ្ជូនទៅតាមផ្លូវគោក នៃភាគីចុះកិច្ចសន្យា ដែលចរាចរឆ្លងកាត់ធ្វើឡើងកាត់តាមទឹកដី នៃភាគីនោះ ។

មាត្រាទី ៦
តំរូវការខាងបច្ចេកទេសជាចាំបាច់ទាំងឡាយ

យានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោក ដែលត្រូវអនុវត្តទៅតាមពិធីសារនេះ មិនត្រូវបានគេអនុញ្ញាតអោយចូលរួមក្នុងការដឹកជញ្ជូនឆ្លងកាត់ លើកលែងតែវាបានបំពេញទៅតាមតំរូវការខាងបច្ចេកទេសចាំបាច់ទាំងឡាយ ដូចដែលគេបានបញ្ជាក់ក្នុងពិធីសារទី ៤ ។

មាត្រាទី ៧
ការរៀបចំស្ថាប័ន

១- កិច្ចប្រជុំមន្ត្រីដឹកជញ្ជូនជាន់ខ្ពស់អាស៊ានត្រូវតែជាអ្នកទទួលខុសត្រូវ សំរាប់ការត្រួតពិនិត្យ តាមដាន ការពិនិត្យមើលឡើងវិញ ការសំរបសំរួល និងការត្រួតត្រាមើល នូវគ្រប់ទិដ្ឋភាពទាំងអស់ដែលជាប់ពាក់ព័ន្ធទៅនឹងការប្រតិបត្តិ ដោយ មានប្រសិទ្ធភាព នៃពិធីសារនេះ ។

២- កិច្ចប្រជុំមន្ត្រីដឹកជញ្ជូនជាន់ខ្ពស់អាស៊ានត្រូវដាក់ស្នើ តាមរយៈលេខាធិការដ្ឋានអាស៊ាន នូវរបាយការណ៍ជាទៀងទាត់ ស្តីពីភាពជឿនលឿន នៃការប្រតិបត្តិ នូវពិធីសារទាំងនេះ ទៅក្រុមប្រឹក្សាគិបាលសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ ដែល បានបង្កើតឡើង ដោយអនុលោមទៅតាមមាត្រាទី ២៩.២ នៃកិច្ចព្រមព្រៀង សំរាប់សកម្មភាពនានាបន្ថែមទៀត ។

៣- លេខាធិការដ្ឋានអាស៊ាន ត្រូវផ្តល់នូវការទ្រទ្រង់ និងជំនួយបច្ចេកទេស ដល់កិច្ចប្រជុំមន្ត្រីដឹកជញ្ជូនជាន់ខ្ពស់របស់អាស៊ាន ក្នុងមុខការ និងការទទួលខុសត្រូវរបស់ខ្លួន ស្របទៅតាមពិធីសារនេះ ។

មាត្រាទី ៨
បទបញ្ញត្តិ

១- ពិធីសារនេះនឹងត្រូវបានគេតំកល់ទុកនៅ អគ្គលេខាធិការដ្ឋានអាស៊ាន ដែលជាអ្នកផ្សព្វផ្សាយជាបន្ទាន់ នូវច្បាប់ចំលង ដែលជាការបញ្ជាក់មួយ ទៅគ្រប់ភាគីចុះកិច្ចសន្យាទាំងអស់ ។

២- ពិធីសារនេះនិងឧបសម្ព័ន្ធទាំងឡាយរបស់វា ត្រូវបង្កើតឡើងបានជាផ្នែករួមបញ្ចូលគ្នាជាមួយកិច្ចព្រមព្រៀង ។

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

៣- ពិធីសារនេះគឺជាកម្មវត្ថុ ក្នុងការធ្វើសច្ចាប័ន ឬ ការយល់ព្រមដោយភាគីចុះកិច្ចសន្យា ។ លិខិតតុបករណ៍ នៃការធ្វើសច្ចាប័ន ឬ ការយល់ព្រមចូល ត្រូវតំកល់ទុកនៅជាមួយអគ្គលេខាធិការអាស៊ាន ដែលជាអ្នកផ្តល់ពត៌មានយ៉ាងរហ័ស ទៅភាគី ចុះកិច្ចសន្យានិមួយៗ នូវការតំកល់ទុកដូចនេះ ។

៤- ពិធីសារនេះ នឹងត្រូវចូលជាធរមាន ក្នុងពេលដែលការតំកល់ទុកនូវលិខិតតុបករណ៍ នៃការធ្វើសច្ចាប័ន ឬ ការយល់ព្រម ពីគ្រប់ភាគីចុះកិច្ចសន្យាទាំងអស់ នៅជាមួយនឹងអគ្គលេខាធិការអាស៊ាន ។

៥- ការធ្វើវិសោធនកម្មណាមួយ ទៅលើប្រការទាំងឡាយ ដែលមានចែងនៅក្នុងពិធីសារនេះ និងឧបសម្ព័ន្ធទាំងឡាយរបស់វា នឹងប្រព្រឹត្តទៅបានតាមរយៈការព្រមព្រៀងគ្នា នៃភាគីជាប់កិច្ចសន្យាទាំងអស់ ។

ដើម្បីទុកជាសក្ខីភាពនៅទីនេះ ហត្ថលេខីខាងក្រោម ដែលបានទទួលសិទ្ធប្រទានយ៉ាងត្រឹមត្រូវ ដើម្បីចុះហត្ថលេខាពីរដ្ឋាភិបាលរបស់ពួកគេទាំងឡាយរៀងៗខ្លួន បានចុះហត្ថលេខាលើពិធីសារទី ៣ ស្តីពីប្រភេទ និងបរិមាណយានយន្តផ្លូវគោក ដើម្បីអនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសំរួលទំនិញឆ្លងកាត់ ។

ធ្វើនៅ. ទីក្រុងហាណូយ. វៀតណាម នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩ ជាច្បាប់ទោលតែមួយគត់ សរសេរជាភាសាអង់គ្លេស ។

....
PENIN DATO HAJI ZAKARIA SULAIMAN
រដ្ឋមន្ត្រីគមនាគមន៍
ព្រុយណេដារូសាឡាម

....
KHY TAINGLIM
រដ្ឋមន្ត្រីសាធារណការ និងដឹកជញ្ជូន
ព្រះរាជាណាចក្រកម្ពុជា

....
AGUM GUMELAR
អគ្គលេខាធិការ ក្រសួងគមនាគមន៍
សាធារណរដ្ឋឥណ្ឌូណេស៊ី

01/09/99 Protocol-3
ពង្រាងបញ្ចប់លើកទី ១

....

PHAO BOUNNAPHAL
រដ្ឋមន្ត្រីគមនាគមន៍, ដឹកជញ្ជូន, ប្រៃសណីយ៍ និងសំណង់
សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

....

DATO' SERI DR. LING LIONG SIK
រដ្ឋមន្ត្រីដឹកជញ្ជូន
ម៉ាឡេស៊ី

....

MAJ GEN HLA MYINT SWE
រដ្ឋមន្ត្រីដឹកជញ្ជូន
សហភាពមីយ៉ាន់ម៉ា

....

VICENTE C. RIVERA, JR.
រដ្ឋលេខាធិការ ដឹកជញ្ជូន និងគមនាគមន៍
សាធារណរដ្ឋហ្វីលីពីន

....

YEO CHEOW TONG
រដ្ឋមន្ត្រីគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាន
សាធារណរដ្ឋសិង្ហបុរី

....

SUTHEP THAUGSUBAN
រដ្ឋមន្ត្រីដឹកជញ្ជូន និងគមនាគមន៍
ព្រះរាជាណាចក្រថៃឡង់ដ៍

....

LE NGOC HOAN
រដ្ឋមន្ត្រីដឹកជញ្ជូន
សាធារណរដ្ឋសង្គមនិយមវៀតណាម

01/09'99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

ឧបសម្ព័ន្ធទី ១

[ប្រការទី ៣(២)]

ប្រភេទនានាឧទាហរណ៍ នៃយានយន្ត

យានយន្តដឹកជញ្ជូនឆ្លងកាត់លើផ្លូវគោក ដែលត្រូវបានគេអនុញ្ញាត តាមពិធីសារនេះ ត្រូវមានប្រភេទទាំងឡាយដូចខាងក្រោម :

១- " Rigid Motor Vehicle " " យានយន្តជាប់រឹងគ្មានតំណ " មានន័យថា ជាយានយន្តមួយផ្សេងអំពីយានយន្ត ជាក្បាលសណ្តោង ឬជាយានយន្តមានតំណចល័ត ជាពិសេសគឺជាយានយន្ត ពាណិជ្ជកម្មមួយ ដែលទទួលយកបន្ទុកទំនិញ នៅពីលើភ្លៅរបស់វា ។

២- " Articulated Vehicle " mean a prime mover drawing a semi-trailer

៣- "រ៉ឺម៉កពាក់កណ្តាលសណ្តោង " មានន័យថា ជាយានយន្តមួយដែលអូសទាញ ឬសណ្តោងដោយយានយន្ត (រថយន្ត) មួយនៅក្នុងស្ថានភាពមួយ ដែលផ្នែកនៃរ៉ឺម៉កត្រូវបានដាក់ភ្ជាប់ពីលើយានយន្តនោះ ហើយដែលផ្នែកដ៏ធំនៃទំងន់រ៉ឺម៉ក និងបន្ទុករបស់វា បត់បែនបានទៅតាមយានយន្ត ។

សំរាប់ជាគោលបំណង នៃពិធីសារនេះ យានយន្តជាប់រឹងគ្មានតំណ " Rigid Motor Vehicle " និងយានយន្តមានតំណ " Articulated Vehicle " ត្រូវបានគេចាត់ថ្នាក់ដូចខាងក្រោម :

- រថយន្តទ្រុងដែលមានក្លឹតសៀល ឬ " ក្លឹតត្រា "	Boxed sealed
- យានយន្ត បង្កកដែលមាន ក្លឹតសៀល ឬ " ក្លឹតត្រា "	Refrigerated sealed
- យានយន្តស៊ីទែន ដែលមានក្លឹតសៀល ឬ " ក្លឹតត្រា "	Tanker sealed
- យានយន្តដឹកកុងតែន័រ ដែលមានក្លឹតសៀល ឬ " ក្លឹតត្រា "	Container sealed

ដែលមាន "ក្លឹតសៀល " ឬ " ក្លឹតត្រា " ត្រូវបានគេកំណត់ជាយានយន្តមួយដែលមានធុង ឬទ្រុងត្រូវបានគេសាងសង់ ឬបំពាក់ឡើងក្នុងសណ្ឋានដូចនេះថា :

ក- សៀល ឬត្រាក្លឹតរបស់គេយអាចអោយគេបិទភ្ជាប់ទៅនឹងយានយន្តនោះ បានដោយស្រួល និងមានប្រសិទ្ធភាព ។

ខ- ទំនិញពុំអាចអោយគេលើកផ្ទេរប្តូរ ឬ ប្រើប្រាស់ជាលើកទី ១ ដោយផ្នែកដែលក្លិតសៀល ឬ ត្រា នៃយានយន្ត ពុំមានមើលឃើញការចេញស្នាម នៃការបើកដោយខុសច្បាប់ ឬ ក៏ពុំមានការបែកបាក់ នូវស៊ីលរបស់គយ ។

គ- វាពុំមានកន្លែងលាក់បាំងលើយានយន្ត ដែលគេអាចលាក់ទំនិញបាន ។

ឃ- គ្រប់កន្លែងទាំងអស់លើយានយន្ត ដែលអាចផ្ទុកទំនិញបាន ត្រូវអាចអោយគេចូលទៅដល់បាន ដោយស្រួល សំរាប់ការត្រួតពិនិត្យគយ ។

PROTOCOL 3

TYPES AND QUANTITY OF ROAD VEHICLES

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, Lao People's Democratic Republic, Malaysia, Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand and the Socialist Republic of Vietnam, Member States of the Association of Southeast Asian Nations (hereinafter referred to as "Contracting Parties");

RECALLING the ASEAN Framework Agreement on the Facilitation of Goods in Transit signed on 16 December 1998 in Hanoi, Vietnam (hereinafter referred to as "the Agreement"),

RECOGNISING that Articles 9 and 25 thereof provide for the conclusion of implementing Protocols which shall form integral parts of the Agreement;

RECALLING further the Hanoi Plan of Action which was adopted by the Heads of State and Government of ASEAN at the Sixth ASEAN Summit in Hanoi, Vietnam on 16 December 1998 stipulates to operationalise the Agreement by the year 2000;

NOW, WHEREFORE, the Contracting Parties have agreed as follows:

CERTIFIED COPY

Article 1
Definitions

For the purposes of this Protocol:

(a) "Transit transport operators" means owners, drivers and/or agents of road transit transport vehicles who (1) have the appropriate national permit or licence to operate transport services and who have a proven compliance record to the rules and procedures under the said permit or licence, and (2) are duly registered as transit transport operators by the respective National Transit Transport Coordinating Committee (NTTCC);

(b) "Road transit transport vehicle" means the type of road vehicles specified under Article 3 herein for the use of carrying goods across the territory of one or more Contracting Parties, when the passage across such territory or territories, with or without transshipment, warehousing, breaking bulk or change in the mode of transport, is only a portion of a complete journey beginning and terminating beyond the frontier of one or more Contracting Parties across whose territory the vehicle passes;

(c) "Transit transport" shall have the meaning assigned to it in the Agreement;

(d) "Protocol 4" means Protocol 4 – Technical Requirements of Vehicles made pursuant to the Agreement.

CERTIFIED COPY
SECRETARY GENERAL OF ASEAN

Article 2
Scope of Application

1. Pursuant to Article 9.2 of the Agreement, the Contracting Parties hereby agree to apply the provisions of this Protocol to a road transit transport vehicle engaging in transit transport.

2 This Protocol shall apply to all road transit transport vehicles and transit transport operators as defined in Article 1 of this Protocol.

Article 3
Types of Vehicle

The Contracting Parties hereby agree that any transit transport operators shall not be permitted to engage in transit transport using road vehicles other than those specified as road transit transport vehicles in Annex 1.

Article 4
Quantity

Pursuant to Article 9.2 of the Agreement, the Contracting Parties hereby agree that the number of road transit transport vehicles which shall be allowed to be used for transit transport shall be no more than sixty (60) vehicles per Contracting Party. Thereafter, the quantity of road transit transport vehicles shall be discussed from time to time between the Contracting Parties.

CERTIFIED COPY SECRETARY GENERAL OF ASEAN

Article 5
Obligations

1. Subject to Article 24 of the Agreement, the Contracting Parties hereby agree to authorize the unhindered access and movement of road transit transport vehicles on designated transit transport routes.

2. The Contracting Parties shall take appropriate measures to ensure that their respective road transit transport vehicles comply with the road traffic rules and regulations of the Contracting Party across whose territory the vehicle passes.

Article 6
Mandatory Technical Requirements

The road transport transit vehicle to which this Protocol applies shall not be allowed to engage in transit transport unless it complies with the Mandatory Technical Requirements as specified in Protocol 4.

Article 7
Institutional Arrangements

1. The ASEAN Senior Transport Officials Meeting shall be the responsible body for the monitoring, review, coordination and supervision of all aspects relating to the effective implementation of this Protocol.

CERTIFIED COPY ... OF ASEAN

2. The ASEAN Senior Transport Officials Meeting shall submit, through the ASEAN Secretariat, regular reports of the progress of implementation of this Protocol to the Transit Transport Coordinating Board established pursuant to Article 29 2 of the Agreement, for further action.

3. The ASEAN Secretariat shall provide the necessary technical support and assistance to the ASEAN Senior Transport Officials Meeting in its functions and responsibilities under this Protocol.

Article 8

Final Provisions

1 This Protocol shall be deposited with the Secretary-General of ASEAN who shall promptly furnish a certified copy thereof to each Contracting Party

2 This Protocol and its Annex shall form an integral part of the Agreement

3 This Protocol is subject to ratification or acceptance by the Contracting Parties. The Instrument of Ratification or Acceptance shall be deposited with the Secretary-General of ASEAN who shall promptly inform each Contracting Party of such deposit.

4. This Protocol shall enter into force upon the deposit of Instruments of Ratification or Acceptance by all Contracting Parties with the Secretary-General of ASEAN.

5. Any amendment to the provisions of this Protocol and its Annex shall be effected by consent of all the Contracting Parties.

CERTIFIED COPY SECRETARY GENERAL OF ASEAN

IN WITNESS WHEREOF, the undersigned, being duly authorized to sign by their respective Governments, have signed Protocol 3 on the Types and Quantity of Road Vehicles to implement the ASEAN Framework Agreement on the Facilitation of Goods in Transit

DONE at Hanoi, Vietnam on the 15th day of September 1999 in a single copy in the English language

PEHIN DATO HAJI ZAKARIA SULAIMAN
Minister of Communications
Brunei Darussalam

KHY TAINGLIM
Minister of Public Works and Transport
Kingdom of Cambodia

ANWAR SUPRIJADI
Secretary General
Ministry of Communications
Republic of Indonesia

PHAO BOUNNAPHOL
Minister of Communication, Transport, Post and Construction
Lao People's Democratic Republic

CERTIFIED COPY

DATO' SERI DR. LING LIONG SIK
Minister of Transport
Malaysia

MAJ. GEN. HLA MYINT SWE
Minister of Transport
Union of Myanmar

VICENTE C. RIVERA, JR.
Secretary of Transportation and Communications
Republic of the Philippines

YEO CHEOW TONG
Minister for Communications and Information Technology
Republic of Singapore

SUTHEP THAUGSUBAN
Minister of Transport and Communications
Kingdom of Thailand

LE NGOC HOAN
Minister of Transport
Socialist Republic of Vietnam

CERTIFIED COPY
SECRETARY GENERAL OF ASEAN

Annex 1

Types of Vehicle

The road transit transport vehicles which are allowed under this Protocol shall fall into the following types:-

1. "Rigid Motor Vehicle" means a motor vehicle other than an articulated vehicle, particularly a commercial vehicle carrying the payload on its own axles.

2 "Articulated vehicle" means a prime mover drawing a semi-trailer

3. "Semi-trailer" means a vehicle drawn by a motor vehicle in such a manner that part of the trailer is superimposed on the motor vehicle and a substantial part of the weight of the trailer and its load is borne by the motor vehicle.

For the purpose of this Protocol, rigid motor vehicles and articulated vehicles are classified into:

- Boxed
- Refrigerated
- Tanker
- Container

} SEALED

Where sealed vehicle is defined as a vehicle the load compartment of which is constructed and equipped in such a manner that:

a. Customs seal can be easily and effectively affixed to it;

b No goods can be removed, or introduced into, the sealed part of the vehicle without leaving visible traces of tampering or without breaking the Customs seal;

c. It contains no concealed space where goods may be hidden; and

d. All spaces capable of holding goods are readily accessible for Customs inspection.

CERTIFIED COPY

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ
និង ដឹកជញ្ជូន

លេខ: 1084 សក

រាជធានីភ្នំពេញ, ថ្ងៃទី 23 ខែ 6 ឆ្នាំ 2005

សូមគោរពជូន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កម្មវត្ថុ : សំណើសុំពិនិត្យសំរេច និងសុំសច្ចាប័នជាថ្មីពីសភាជាតិលើពិធីសារអាស៊ានចំនួន ០២ ។

យោង : - លិខិតលេខ ៩២៥ លសកបច ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។
- សិទ្ធិប្រទានលេខ ៤៣ សប្រទ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថា កាលពីថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩ កន្លងទៅ នៅក្នុងកិច្ចប្រជុំលើកទី ៥ រដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន នៅទីក្រុងហាណូយ ប្រទេសវៀតណាម ក្រសួងសាធារណការ និងដឹកជញ្ជូន បានចុះហត្ថលេខាលើពិធីសារចំនួន ០២ ដូចខាងក្រោម សំរាប់អនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសំរួលទំនិញឆ្លងកាត់ :

១- ពិធីសារទី ៣ : ស្តីពីការកំណត់ប្រភេទ និងបរិមាណរថយន្តដឹកជញ្ជូនឆ្លងកាត់

២- ពិធីសារទី ៤ : ស្តីពីតំរូវការបច្ចេកទេសរបស់រថយន្តដឹកជញ្ជូនឆ្លងកាត់

សូមជំរាបជូនថា ពិធីសារទាំងពីរនេះត្រូវបានសភាជាតិនីតិកាលទី២ ពិនិត្យ និងអនុម័តម្តងរួចហើយ និង បានបញ្ជូនទៅព្រឹទ្ធសភា ដើម្បីពិនិត្យ អនុម័តកាលពីឆ្នាំ ២០០២-២០០៣ កន្លងទៅ ។ ប៉ុន្តែពិធីសារទាំងពីរត្រូវបានសភាជាតិនីតិកាលទី ៣ បញ្ជូនមករាជរដ្ឋាភិបាលវិញ និងស្នើអោយក្រសួង-ស្ថាប័នពាក់ព័ន្ធ ពិនិត្យ និងស្នើសុំការអនុម័តពីសភាជាតិជាថ្មីឡើងវិញ ។

អាស្រ័យហេតុនេះ សូមឯកឧត្តម មេត្តាពិនិត្យសំរេច និងស្នើសុំទៅសភាជាតិជាថ្មី ដើម្បីផ្តល់សច្ចាប័ន លើពិធីសារខាងលើនេះ តាមការគួរ ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
រដ្ឋមន្ត្រីស្តីទី

ស៊ុខ ហេង

ចំលងជូន
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឯកឧត្តមរដ្ឋលេខាធិកា-អនុរដ្ឋលេខាធិការ
- ឯកឧត្តម អគ្គនាយក
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៣ .ស/បក

M.P.W.T
5180
14 SEP. 1999

សិទ្ធិប្រទាន

_រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ប្រគល់សិទ្ធិពេញសមត្ថភាពជូនឯកឧត្តម ឃី តាំងលីម រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីពិភាក្សា និងចុះហត្ថលេខាក្នុងនាមរាជរដ្ឋាភិបាលកម្ពុជាលើ :

_ពិធីសារទី ១ : ស្ដីពីការកំណត់ផ្លូវ និងមធ្យោបាយដឹកជញ្ជូនឆ្លងកាត់

_ពិធីសារទី ៣ : ស្ដីពីការកំណត់ប្រភេទ និងបរិមាណរថយន្តដឹកជញ្ជូនឆ្លងកាត់

_ពិធីសារទី ៤ : ស្ដីពីតម្រូវការបច្ចេកទេសរបស់រថយន្តដឹកជញ្ជូនឆ្លងកាត់

_កិច្ចព្រមព្រៀងថ្នាក់រដ្ឋមន្ត្រី ស្ដីពីការអភិវឌ្ឍន៍បណ្ដាញផ្លូវអាស៊ានហាយវេ ជាមួយប្រទេសជាសមាជិកអាស៊ាន ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១៥ និង ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ខែ កញ្ញា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រីស្ដីទី

ស ខេង

ព្រះរាជាណាចក្រកម្ពុជា

KINGDOM OF CAMBODIA

រាជរដ្ឋាភិបាល កម្ពុជា
Royal Government of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

Nº 43 DF.P

DELEGATION OF FULL POWER

The Royal Government of Cambodia delegates herewith to H. E. Mr. KHY TAINGLIM, Minister of Public Works and Transport, the full powers to negociate and sign the following documents with the ASEAN member governments :

-Protocol 1: On the Designation of Road Transit Transport Routes and Facilities

-Protocol 3. On Types and Quantity of Road Vehicles

-Protocol 4. On Technical Requirement of Road Vehicles

-Ministerial Understanding on the Development of the ASEAN Highway Network Projet

In witness wherof, the undersigned, the Acting Prime Minister of the Kingdom of Cambodia, with full powers duly entrusted to him, has signed this full power.

Phnom Penh, 13th September 1999

SAR KHENG
Acting Prime Minister

នស/រកត/០២០៧/០៦០

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ

១- ឯកឧត្តម ឌិត មុន្នី

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ

១- ឯកឧត្តម អង្គ វង្សវឌ្ឍនា
២- ឯកឧត្តម អ៊ិត ឌីតុន
៣- លោកជំទាវ លី វួចឡេង
៤- ឯកឧត្តម ហង់ វ៉ាគេន
៥- ឯកឧត្តម វៀល មួន
៦- ឯកឧត្តម ឌី ឈោង

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ

១- ឯកឧត្តម អ៊ុំ សារិទ្ធ

ឃ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ

១- ឯកឧត្តម ច័ន្ទ មនោ
២- លោក សំ ប្រជាមានិត
៣- លោក សម ម៉ិនថុន

៣រល.០៧០២.០៧០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៧

លេខ: ០០៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] វិនកេន

នស/រកត/០២០៧/០៦៧

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស . រកត . ០៧០៤ . ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ នស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៧

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតាំងស៊ុបក្នុងក្របខ័ណ្ឌនៃអង្គចៅក្រម ចំពោះលោក លោកស្រី ចៅក្រម-ព្រះរាជអាជ្ញារង កម្មសិក្សា ជាចៅក្រម ជាព្រះរាជអាជ្ញារង និងត្រូវចាត់ឱ្យទៅបំរើការងារ នៅតាមអង្គភាព និងសាលាជំរះក្តីនានា ដូចមានរាយនាមខាងក្រោម :

ក-ការិយាល័យរដ្ឋបាល នៃអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា

១- លោក លឹម សុគន្ធា ជាចៅក្រម

២- លោក សេខ ប៊ុនឃាង ជាព្រះរាជអាជ្ញារង

ខ-តុលាការ_អយ្យការក្រុងភ្នំពេញ

១-លោកស្រី ចាំង ស៊ុណនាត ជាចៅក្រម

២-លោក គួ ពៅស៊ុន ជាចៅក្រម

៣-លោក ម្លិះ សុផល ជាព្រះរាជអាជ្ញារង

គ-តុលាការ_អយ្យការខេត្តកណ្ដាល

១-លោកស្រី សែម សក្តិគុន្សា ជាចៅក្រម

២-លោក ឃុន លាងម៉េង ជាចៅក្រម

៣-លោក អ៊ុត សុធា ជាចៅក្រម

៤-លោក យូ ម៉ុនណារ ជាចៅក្រម

៥-លោក កោ វណ្ណី ជាចៅក្រម

៦-លោក ច្រឹង ខ្មៅ ជាព្រះរាជអាជ្ញារង

៧-លោកស្រី ចាតស្វ រស្មី ជាព្រះរាជអាជ្ញារង

៨-លោក កើត វណ្ណារ៉េត ជាព្រះរាជអាជ្ញារង

៩-លោក គី ម៉ុន្នណ្ណារ៉ា ជាព្រះរាជអាជ្ញារង

ឃ-តុលាការ_អយ្យការខេត្តសៀមរាប

១-លោក ស្វស ឡា ជាចៅក្រម

២-លោក ខ្វន ណារ៉ា ជាចៅក្រម

៣-លោក ម៉ុល សំអឿន ជាចៅក្រម

៤-លោក ខួន សាន ជាព្រះរាជអាជ្ញារង

៥-លោក តួច សុគន្ធី ជាព្រះរាជអាជ្ញារង

ង-តុលាការ_អយ្យការខេត្តបាត់ដំបង

១-លោក ឌុច សុខសារិន ជាចៅក្រម

២-លោក អ៊ឹ ចាន់ថុល	ជាចៅក្រម
៣-លោក គី ឫទ្ធី	ជាចៅក្រម
៤-លោក ផាន់ ចន្ទរ៉ាត្ន	ជាចៅក្រម
៥-លោក គួយ គាន់យ៉ា	ជាព្រះរាជអាជ្ញារង
៦-លោក អ៊ុយ សំអាវ	ជាព្រះរាជអាជ្ញារង

ច-តុលាការ អយ្យការខេត្តកំពង់ចាម

១-លោក ផ្លូង ចន្ទា	ជាចៅក្រម
២-លោក ចាយ ចំនួតារាចន្ទា	ជាចៅក្រម
៣-លោកស្រី គីម លុយ	ជាចៅក្រម
៤-លោក ជុំ សែនសន្ធា	ជាព្រះរាជអាជ្ញារង

ឆ-តុលាការ អយ្យការខេត្តតាកែវ

១-លោក ហុក វ៉ាន់ធីណា	ជាចៅក្រម
២-លោក យន់ ណារ៉ុង	ជាចៅក្រម
៣-លោក មាស ចំនួពិសិដ្ឋ	ជាព្រះរាជអាជ្ញារង
៤-លោក ចំនួ រង្សី	ជាព្រះរាជអាជ្ញារង

ជ-តុលាការ អយ្យការខេត្តកំពត

១-លោក សេង នាង	ជាចៅក្រម
២-លោក លឹម មករទ្ធ	ជាចៅក្រម
៣-លោក អៀង សៀង	ជាចៅក្រម
៤-លោក គុម ឈុនហេង	ជាព្រះរាជអាជ្ញារង

ឈ-តុលាការ អយ្យការក្រុងព្រះសីហនុ

១-លោក ម្លូង សំណាង	ជាចៅក្រម

២-លោក តាំង ស៊ុនឡាយ ជាចៅក្រម

៣-លោក ឈាង ស្រេង ជាព្រះរាជអាជ្ញារង

ញ-តុលាការខេត្តកំពង់ស្ពឺ

១-លោកស្រី ស៊ុំ វណ្ណនី ជាចៅក្រម

២-លោកស្រី ខៀវ សុខា ជាចៅក្រម

ដ-តុលាការ-អយ្យការខេត្តកំពង់ឆ្នាំង

១-លោក ទើង ហ៊ត់ ជាចៅក្រម

២-លោក ហេង លុយ ជាព្រះរាជអាជ្ញារង

ឋ-តុលាការ-អយ្យការខេត្តព្រៃវែង

១-លោក អ៊ុក សុវណ្ណារិទ្ធ ជាចៅក្រម

២-លោក សែត វិសិដ្ឋមុនី ជាចៅក្រម

៣-លោក ចំនួ តារាស្មី ជាព្រះរាជអាជ្ញារង

ឌ-តុលាការ-អយ្យការខេត្តស្វាយរៀង

១-លោក លី លីមម៉េង ជាចៅក្រម

២-លោក ទ្រី សុភ័ត ជាចៅក្រម

៣-លោក កែវ សុធា ជាព្រះរាជអាជ្ញារង

ឍ-តុលាការខេត្តបន្ទាយមានជ័យ

១-លោក អ៊ាក ផល្លា ជាចៅក្រម

ណ-តុលាការខេត្តកំពង់ធំ

១-លោក ជុំ ស ជាចៅក្រម

គ-អយ្យការខេត្តក្រចេះ

១-លោក គង់ សំសារិត ជាព្រះរាជអាជ្ញារង

ឃ-តុលាការខេត្តស្ទឹងត្រែង

១-លោក គង់ ចំនុះខមរិន្ទ ជាចៅក្រម

ង-តុលាការខេត្តកោះកុង

១-លោក លាង សំណាត់ ជាចៅក្រម

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត អោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣/រល.០៧០២.០៧៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

លេខ ១០៧ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៧/០៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស. រកត. ០៧០៤. ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ នស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៧

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំង :

១-លោក គង់ សែន	ចៅក្រមតុលាការក្រុងភ្នំពេញ ជាព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តកំពង់ស្ពឺ ។
២-លោក គុប ចំនួសិរីទុធ	ចៅក្រមតុលាការខេត្តបន្ទាយមានជ័យ ជាព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តពោធិសាត់ ។
៣-លោក ញ៉ូង ធុល	ព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តបន្ទាយមានជ័យ ជាចៅក្រមសាលាឧទ្ធរណ៍ ។
៤-លោក ខ៊ែត សារ៉ែត	ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការក្រុងភ្នំពេញ ជាព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ។

៥-លោក ម៉ី ម៉ិនហាន ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ជាព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

៣៩/ល. ០៧០២. ០៧៤

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

លេខៈ ១០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

នស/រកត/០២០៧/០៦៩

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស. រកត. ០៧០៤. ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ នស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៧

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានផ្ទេរភារកិច្ច :

១-លោក មុិច ឈឿត អនុប្រធានតុលាការខេត្តបាត់ដំបង អោយទៅបំរើការងារជាអនុប្រធានតុលាការខេត្តកំពត ។

២-លោក ឌិត ឡាយយី អនុប្រធានតុលាការខេត្តកំពត ឱ្យទៅបំរើការងារជាអនុប្រធានតុលាការខេត្តបាត់ដំបង ។

៣-លោក ឡេ ស៊ីថុន អនុប្រធានតុលាការខេត្តកំពង់ឆ្នាំង អោយទៅបំរើការងារជាអនុប្រធានតុលាការខេត្តកំពង់ធំ ។

៤-លោក សី នុយ អនុប្រធានតុលាការខេត្តកំពង់ធំ ឱ្យទៅបំរើការងារជាអនុប្រធានតុលាការខេត្តកំពង់ឆ្នាំង ។

៥-លោក ចេង ម៉ុនលី	អនុប្រធានតុលាការខេត្តកោះកុង ឱ្យទៅបំរើការងារជាអនុប្រធានតុលាការខេត្តតាកែវ ។
៦-លោក សួន សំណាង	ចៅក្រមតុលាការខេត្តពោធិសាត់ ឱ្យទៅបំរើការងារជាចៅក្រមតុលាការក្រុងភ្នំពេញ ។
៧-លោក ជ័យ សុវណ្ណ	ចៅក្រមតុលាការខេត្តកណ្តាល ឱ្យទៅបំរើការងារជាចៅក្រមតុលាការក្រុងភ្នំពេញ ។
៨-លោក ឌុច ចន្ថា	ចៅក្រមតុលាការខេត្តកំពង់ចាម ឱ្យទៅបំរើការងារជាចៅក្រមតុលាការខេត្តពោធិសាត់ ។
៩-លោក តាន់ គឹមសឿ	ចៅក្រមតុលាការក្រុងព្រះសីហនុ ឱ្យទៅបំរើការងារជាចៅក្រមតុលាការខេត្តកំពត ។
១០-លោក អឿន គឹមឌុល	ចៅក្រមតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ អោយទៅបំរើការងារជាចៅក្រមតុលាការខេត្តតាកែវ ។
១១-លោកស្រី អ៊ិន ម៉ានិត្យ	ចៅក្រមតុលាការខេត្តកំពត អោយទៅបំរើការងារជាចៅក្រមតុលាការក្រុងព្រះសីហនុ ។
១២-លោក សុន នាថធាទី	ចៅក្រមតុលាការខេត្តពោធិសាត់ ឱ្យទៅបំរើការងារជាចៅក្រមតុលាការខេត្តក្រចេះ ។
១៣-លោក គង់ សុខុម	ចៅក្រមតុលាការខេត្តក្រចេះ អោយទៅបំរើការងារជាចៅក្រមតុលាការខេត្តពោធិសាត់ ។
១៤-លោក សុខ លាង	ចៅក្រមតុលាការខេត្តតាកែវ ឱ្យទៅបំរើការងារជាចៅក្រមតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។
១៥-លោក សូ ម៉ាត	ព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ឱ្យទៅបំរើការងារជា ព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តបន្ទាយមានជ័យ ។
១៦-លោក ទ៉ែន យឿន	ព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តកំពង់ស្ពឺ អោយទៅបំរើការងារជា ព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តស្វាយរៀង ។

១៧-លោក ជុំ សំធាន ព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តស្វាយរៀង ឱ្យទៅបំរើការងារជា ព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ។

១៨-លោក ម៉ិត ភារង ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តកំពង់ចាម អោយទៅបំរើការងារជា ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការក្រុងព្រះសីហនុ ។

១៩-លោក សិ សារុន ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តកំពង់ចាម អោយទៅបំរើការងារជា ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តព្រៃវែង ។

២០-លោក ហ៊ុង ប៊ុនជា ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តបាត់ដំបង អោយទៅបំរើការងារជា ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការក្រុងភ្នំពេញ ។

២១-លោក ឈុន ខិន ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការក្រុងព្រះសីហនុ អោយទៅបំរើការងារជា ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តកំពង់ចាម ។

២២-លោក ឈី លន់ អតីតព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តកណ្តាល ដែលបច្ចុប្បន្នកំពុងបំរើការងារនៅក្រសួងយុត្តិធម៌ ជាព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តស្វាយរៀង ។

២៣-លោក មូង សារិន ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តព្រៃវែង អោយទៅបំរើការងារជា ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តកំពង់ចាម ។

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ជករ
នរោត្តម សីហមុនី

នស.០៧០២.០៧៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

លេខ ១០៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ជិនកេន

នស/រកត/០២០៧/០៧០

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស. រកត. ០៧០៤. ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ នស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពី ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៧

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានអនុញ្ញាតឱ្យលោក ហ៊ុន ធីម្ងន្ទិ ចៅក្រមតុលាការខេត្តស្ទឹងត្រែង ចូលបំរើការងារជាចៅក្រមតុលាការខេត្តស្ទឹងត្រែងវិញ ។

មាត្រា ២ : ត្រូវបានអនុញ្ញាតឱ្យលោក ហម ម៉េងសែ ចូលបំរើការងារវិញ និងចាត់ឱ្យទៅបំរើការងារជាចៅក្រមនៅតុលាការខេត្តកោះកុង ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ : ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣ស.០៧០២.០៨០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

លេខៈ ១០៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ជំនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៧/០៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស . រកត . ០៧០៤ . ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ នស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់សំណើសុំបន្តការងាររបស់ចៅក្រម និង ព្រះរាជអាជ្ញា ដែលមានអាយុ ៦០ឆ្នាំ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៧

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានអនុញ្ញាតជូនចៅក្រម និង ព្រះរាជអាជ្ញា ដែលដល់អាយុចូលនិវត្តន៍ ឱ្យនៅបន្តបំរើការងារមួយរយៈ ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម	ជួន ស៊ុនឡេង	អគ្គព្រះរាជអាជ្ញារង នៃមហាអយ្យការអមតុលាការកំពូល
២-ឯកឧត្តម	អ៊ុំ សារិទ្ធ	ចៅក្រុមសាលាឧទ្ធរណ៍
៣-ឯកឧត្តម	ឡោត់ គីមសាន	ចៅក្រុមតុលាការកំពូល

៤-លោក ឈឹម ស៊ីផល ចៅក្រមតុលាការកំពូល

៥-លោក អន សំណាង អនុប្រធានតុលាការខេត្តរតនគិរី

៦-លោកស្រី ប៉េ គឹមយ៉ាង ចៅក្រមតុលាការខេត្តកំពង់ចាម

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នស.០៧០២.០៨១

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

លេខៈ ១០៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ឌីនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៧/០៧២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស. រកត. ០៧០៤. ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ នស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៥/៤០៣ ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការដាក់ឱ្យចូលនិវត្តន៍ចៅក្រម និង ព្រះរាជអាជ្ញា ដែលមានអាយុចាប់ពី ៦០ឆ្នាំឡើង ។
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៧

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដាក់ឱ្យចូលនិវត្តន៍ចៅក្រម ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារង គិតចាប់ពីខែ តុលា ឆ្នាំ ២០០៥ តទៅ ដែលមានរាយនាមដូចខាងក្រោម :

១-លោក រស់ ឡុង	ចៅក្រមសាលាឧទ្ធរណ៍
២-លោក ហ៊ីម អ៊ី	ចៅក្រមតុលាការខេត្តកំពត (ប្រធាន)
៣-លោក ឆេង ផាត់	ព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តកណ្តាល
៤-លោក ម៉ុល នាង	ចៅក្រមសាលាឧទ្ធរណ៍
៥-លោក រិត ហៀន	ចៅក្រមតុលាការខេត្តកំពង់ឆ្នាំង

៦-លោក ឯម គឹមអេង	ចៅក្រមតុលាការខេត្តកំពង់ធំ
៧-លោក សោ សុគីរ	ចៅក្រមតុលាការក្រុងភ្នំពេញ (ប្រធាន)
៨-លោក ឆៀង អួន	ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តស្វាយរៀង
៩-លោក អៀង ឃ្លីន	ចៅក្រមតុលាការខេត្តបន្ទាយមានជ័យ
១០-លោក ចន្ទ ហួន	ចៅក្រមតុលាការខេត្តកោះកុង
១១-លោក ឈុន លីមខន	ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តកំពង់ធំ
១២-លោក ម៉ី ពិន	ព្រះរាជអាជ្ញានៃអយ្យការអមតុលាការខេត្តព្រៃវែង

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត អោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នស.រកត.០៧០២.០៤២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

លេខ: ១០៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៧/០៧៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស . រកត . ០៧០៤ . ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ នស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៧

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានដាក់វិន័យលោក ឌន សុខ អនុប្រធានតុលាការខេត្តរតនគីរី ក្រោមរូបភាព ដាក់ឱ្យចូលនិវត្តន៍មុនកាលកំណត់ ។

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រប.០៧០២.០៨៣

លេខៈ៦៦០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៧
[illegible]

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

[illegible]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..១៣...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៤ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ សន/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- តាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

សម្រេច

ជំពូក ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១ :-

អនុក្រឹត្យនេះកំណត់ តួនាទី មុខងារ សមត្ថកិច្ច និងរៀបចំរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

ជំពូក ២

តួនាទី មុខងារ សមត្ថកិច្ច និងរចនាសម្ព័ន្ធ

មាត្រា ២ :-

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានតួនាទីដ៏សំខាន់ក្នុងការប្រមូលពត៌មាន និងចូលរួមប្រតិបត្តិការប្រឆាំងនឹងការជាំដុះ ការផលិត ការជួញដូរគ្រឿងញៀនខុសច្បាប់ និងសំរបសំរួលរាល់សកម្មភាពត្រួតពិនិត្យគ្រឿងញៀនរបស់អង្គភាពប្រតិបត្តិដទៃទៀត ដើម្បីធានាប្រសិទ្ធភាព និងសុវត្ថិភាពនៃការបង្ក្រាបគ្រឿងញៀនខុសច្បាប់នៅព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងតួនាទីនេះ អគ្គលេខាធិការដ្ឋានមានមុខងារសំខាន់ៗ ដូចតទៅ ÷

១. រៀបចំជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងរាជរដ្ឋាភិបាល នូវយុទ្ធសាស្ត្រ និងផែនការសកម្មភាព បង្ក្រាបការដាំដុះ ការផលិត ការជួញដូរគ្រឿងញៀនខុសច្បាប់ និងការប្រើបំពានគ្រឿងញៀន ដោយសំរបសំរួលឱ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់ក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

២. រ៉ាប់រងការអនុវត្តន៍គោលនយោបាយ សេចក្តីសំរេចរបស់រាជរដ្ឋាភិបាល និងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៣. ជំរុញ និងសំរបសំរួលវិធានការត្រួតពិនិត្យគ្រឿងញៀនដែលរៀបចំឡើងដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ។

៤. រៀបចំជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងរាជរដ្ឋាភិបាលនូវគោលនយោបាយជាតិ ស្តីពីវិធានការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

៥. ធ្វើទំនាក់ទំនងជាមួយនិងរដ្ឋាភិបាលបរទេសនិងអង្គការអន្តរជាតិនានា ក្នុងការត្រួតពិនិត្យគ្រឿងញៀន ។

មាត្រា ៣ :-

នៅក្នុងក្របខ័ណ្ឌនៃការបំពេញតួនាទី និងមុខងាររបស់ខ្លួនខាងលើនេះ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវមានសមត្ថកិច្ចដូចតទៅ :

១. រៀបចំ និងចូលរួមក្នុងកិច្ចពិភាក្សារបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

២. អនុវត្តតាមស្មារតីនៃអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ១៩៦១ ដែលបានធ្វើវិសោធនកម្មដោយពិធីសារឆ្នាំ១៩៧២.អនុសញ្ញាស្តីពីសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ១៩៧១ និងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរខុសច្បាប់នូវគ្រឿងញៀន និងសារធាតុដែលធ្វើឱ្យប៉ះពាល់សរសៃប្រសាទ ឆ្នាំ១៩៨៨ ។

៣. ជំរុញ និងសំរបសំរួលការប្រមូលពត៌មាន និងស្ថិតិដែលកំណត់នៅក្នុងអនុសញ្ញាអន្តរជាតិ ដើម្បីឱ្យស្ថាប័នមានសមត្ថកិច្ច បញ្ជូន និងផ្តល់ពត៌មានទាំងនោះ ទៅអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិដែលមានសមត្ថកិច្ចឱ្យបានទាន់ពេលកំណត់ ។

៤. រៀបចំ និងតាក់តែងនូវសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានទាំងឡាយ ក្នុងវិស័យអប់រំ បង្ការទប់ស្កាត់ និងបង្ក្រាបការដាំដុះ ការផលិត ការធ្វើជំនួញគ្រឿងញៀន ការទាញផលចំណេញពីគ្រឿងញៀន និងការសំអាតប្រាក់ដែលបានមកពីជំនួញគ្រឿងញៀនខុសច្បាប់ ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៥. រៀបចំលិខិតបទដ្ឋានសុវត្ថិភាពនៃការវេចខ្ចប់ ការប្រគល់ទទួល ការរក្សាទុក និងការកំទេចចោលគ្រឿងញៀនដែលចាប់បាន ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៦. ត្រួតពិនិត្យ និងបង្ក្រាបការដាំដុះ ការផលិត ការនាំចូល ការនាំចេញ ការចែកចាយ ការឆ្លងកាត់ ឬការសំចតគ្រឿងញៀន និងសារធាតុផ្សំថ្មីៗទៀតសំរាប់ផលិតគ្រឿងញៀន ឱសថដែលមានសារធាតុ

ញៀន និងថ្នាំញៀនស្របច្បាប់កំណត់ដោយក្រសួងសុខាភិបាល ដោយសហការជាមួយក្រសួង-ស្ថាប័ន និង អង្គការពាក់ព័ន្ធដទៃទៀត ។

៧. តាមដាន និងអនុវត្តច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងបទប្បញ្ញត្តិផ្សេងៗដែលទាក់ទងទៅនឹងបទល្មើសគ្រឿងញៀន ព្រមទាំងចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនៃនីតិវិធីតុលាការ ។

៨. ដាក់ឱ្យដំណើរការនូវប្រព័ន្ធមួយសំរាប់ពិនិត្យ តាមដាន និងវិភាគការប្រើប្រាស់គ្រឿងញៀន ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៩. រៀបចំ និងអនុវត្តកម្មវិធីអប់រំ ផ្សព្វផ្សាយ និងបង្ការកុំឱ្យមានការប្រើបំពានគ្រឿងញៀនដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

១០. សំរបសំរួលសកម្មភាពរបស់រដ្ឋាភិបាល ប្រឆាំងនឹងការសំអាតប្រាក់ដែលទាក់ទងនឹងជំនួញគ្រឿងញៀនខុសច្បាប់ ។

១១. សំរបសំរួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធរៀបចំបង្កើតមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាសំរាប់អ្នកញៀនគ្រឿងញៀន ។

១២. រៀបចំ និងអនុវត្តកម្មវិធី ព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន ដើម្បីជួយឱ្យពួកគេមានឱកាសបានមករស់នៅក្នុងភាពធម្មតាឡើងវិញ ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធ ។

១៣. រៀបចំមជ្ឈមណ្ឌលពតិមានគ្រឿងញៀន ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

១៤. រៀបចំកម្មវិធីបណ្តុះបណ្តាលដល់មន្ត្រីរាជការរបស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

មាត្រា ៤ :.

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានរចនាសម្ព័ន្ធជានាយកដ្ឋាន និង អង្គភាពដែលមានថ្នាក់ស្មើនាយកដ្ឋានរួមមាន ÷

១- នាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ ·

២- នាយកដ្ឋាន ផែនការ និងបណ្តុះបណ្តាល

៣- នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ

៤- នាយកដ្ឋានអនុវត្តច្បាប់

៥- នាយកដ្ឋាន នីតិកម្ម អប់រំ និងស្តារនីតិសម្បទា

៦- នាយកដ្ឋាន ស្រាវជ្រាវ និងត្រួតពិនិត្យ

៧- មន្ទីរពិសោធន៍គ្រឿងញៀន

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ៥ :-

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូបដែលមានអគ្គលេខាធិការរងជាជំនួយការ ។

មាត្រា ៦ :-

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានសិទ្ធិធ្វើត្រាប្រើប្រាស់តាមសេចក្តីត្រូវការ ។

អគ្គលេខាធិការមានសិទ្ធិធ្វើសេចក្តីសំរេចតែងតាំង ឬ ផ្លាស់ប្តូរតំណែងនូវមន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន ចាប់ពីថ្នាក់ប្រធានផ្នែកចុះ។ ចំពោះការតែងតាំង ឬ ផ្លាស់ប្តូរតំណែងមន្ត្រីរាជការចាប់ពីអនុប្រធានការិយាល័យឡើងទៅ អគ្គលេខាធិការមានភារកិច្ចស្នើសុំប្រធានអាជ្ញាធរជាតិ ដើម្បីសំរេច ។

ក្នុងករណីចាំបាច់ អគ្គលេខាធិការ អាចមានសិទ្ធិជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាអោយមកបំពេញការងារនៅអគ្គលេខាធិការដ្ឋានតាមលក្ខខណ្ឌកំណត់ ។

ជំពូក ៣
នាយកដ្ឋាន

មាត្រា ៧ :- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ ៖

១. សំរបសំរួលរាល់សកម្មភាពរបស់អគ្គលេខាធិការដ្ឋាន ។
២. គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន ។
៣. សរុប និងធ្វើរបាយការណ៍សភាពការណ៍គ្រឿងញៀន និងសកម្មភាពការងាររបស់អាជ្ញាធរជាតិ អគ្គលេខាធិការដ្ឋាន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង ។
៤. គ្រប់គ្រងផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងមន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន ។
៥. លើក និងអនុវត្តគំរោងថវិកាប្រចាំឆ្នាំរបស់អគ្គលេខាធិការដ្ឋាន ។
៦. ប្រមូលផ្តុំចំណូល និងចំណាយរបស់អគ្គលេខាធិការដ្ឋាន ។
៧. តាមដាន និងរំលឹកការអនុវត្តន៍ថវិកា និងគ្រប់គ្រងគណនីរបស់អគ្គលេខាធិការដ្ឋាន ។
៨. គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ ធ្វើបញ្ជីសារពើភ័ណ្ឌរបស់អគ្គលេខាធិការដ្ឋាន ។
៩. រៀបចំ និងបើកប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការរបស់អគ្គលេខាធិការដ្ឋាន ។
១០. ទទួល និងបែងចែកបរិក្ខារ ជូនដល់អង្គភាពទៅតាមកម្មវិធីចំណាយរបស់អគ្គលេខាធិការដ្ឋាន ។
១១. រៀបចំនិងទទួលរាល់កិច្ចប្រជុំរបស់អគ្គលេខាធិការដ្ឋាននិងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។
១២. ធានាប្រសិទ្ធភាពផ្នែករដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន ។

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានជា ជំនួយការ ។

មាត្រា ៨ :- នាយកដ្ឋានផែនការ និងបណ្តុះបណ្តាល មានភារកិច្ចដូចតទៅ ៖

១. រៀបចំយុទ្ធសាស្ត្រ និងលើកផែនការ គោលនយោបាយក្នុងការបង្ក្រាបការដាំដុះ ការផលិត ការជួញដូរ ការនាំចេញ និងនាំចូល ការដឹកជញ្ជូន នូវគ្រឿងញៀនខុសច្បាប់ ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

២. រៀបចំគំរោងសកម្មភាព ដើម្បីអនុវត្តបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ ដែលបានធ្វើវិសោធនកម្មដោយពិធីសារ ឆ្នាំ ១៩៧២, អនុសញ្ញា ស្តីពីសារធាតុ

ដែលធ្វើអោយប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ឆ្នាំ ១៩៧១ និងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរខុសច្បាប់នូវគ្រឿងញៀន និងសារធាតុដែលធ្វើអោយប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ឆ្នាំ ១៩៨៨ ។

៣. ពិនិត្យតាមដានការអនុវត្តនីគោលនយោបាយ និងសេចក្តីសំរេចរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៤. រៀបចំផែនការថ្នាក់ជាតិ និងគ្រប់គ្រងគំរោងដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៥. រៀបចំ និងអនុវត្តនយោបាយ ស្តីពីការបណ្តុះបណ្តាលដល់មន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

៦. សហការជាមួយអង្គការជាតិ និងអន្តរជាតិដើម្បីយល់ដឹងអំពីគោលការណ៍របស់តំបន់ អនុតំបន់ និងអន្តរជាតិ ស្តីពីគ្រឿងញៀន ។

នាយកដ្ឋានផែនការ និងបណ្តុះបណ្តាល ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាន ជាជំនួយការ ។

មាត្រា ៩ ៈ- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដូចតទៅ ៖

១. ទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាលបរទេស និងអង្គការអនុតំបន់ ឬអន្តរជាតិនានា ។

២. បញ្ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិនូវអាស័យដ្ឋានរបស់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញាអន្តរជាតិ ។

៣. សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការបញ្ជូនពត៌មាន និងស្ថិតិដែលកំណត់នៅក្នុងអនុសញ្ញាអន្តរជាតិ ទៅអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិដែលមានសមត្ថកិច្ច ។

៤. ចូលរួមក្នុងសកម្មភាពប្រចាំអនុតំបន់នានា ឬអន្តរជាតិ ។

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានជាជំនួយការ ។

មាត្រា ១០ :- នាយកដ្ឋានអនុវត្តច្បាប់ មានភារកិច្ចដូចតទៅ ÷

១. ស្រាវជ្រាវ និងប្រមូលពតិមានពាក់ពន្ធ័នឹងគ្រឿងញៀន ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

២. ត្រួតពិនិត្យ និងបង្រ្កាបការជាំដុះ ការផលិត ការនាំចូល ការនាំចេញ ការចែកចាយ ការឆ្លងកាត់ ឬសំចតគ្រឿងញៀន ឱសថដែលមានសារធាតុញៀន និងថ្នាំញៀនស្របច្បាប់កំណត់ដោយក្រសួងសុខាភិបាល ដោយសហការជាមួយ ក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៣. តាមដាន និងអនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងសាលក្រមតុលាការដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ។

៤. រៀបចំលិខិតបទដ្ឋានសុវត្ថិភាពស្តីពីការវេចខ្ចប់ ការប្រគល់ទទួល ការរក្សាទុក និងការកំទេចចោលគ្រឿងញៀនដែលចាប់បាន ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៥ រៀបចំ និងគ្រប់គ្រងមជ្ឈមណ្ឌលពតិមានគ្រឿងញៀន ។

៦. សំរបសំរួល និងចូលរួមក្នុងការបង្កើត និងអនុវត្តនូវកម្មវិធីប្រឆាំងនឹងការសំអាតប្រាក់ដែលបានមកពីជំនួញគ្រឿងញៀនខុសច្បាប់ ។

នាយកដ្ឋានអនុវត្តច្បាប់ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានជាជំនួយការ ។

មាត្រា ១១ :- នាយកដ្ឋាន នីតិកម្ម អប់រំ និងស្តារនីតិសម្បទា មានភារកិច្ចដូចតទៅ ÷

១. រៀបចំ និងអនុវត្តកម្មវិធីអប់រំបង្ការ ទប់ស្កាត់ និងកាត់បន្ថយការប្រើបំពានគ្រឿងញៀននៅក្នុងប្រទេស ដោយសំរបសំរួល និងសហការឱ្យបានល្អជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

២. រៀបចំ សំរបសំរួល និងអនុវត្តកម្មវិធីសំរាប់ទទួលព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងជួយឱ្យពួកគេក្លាយទៅជាពលរដ្ឋល្អរបស់សង្គមដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៣. ជំរុញ និងលើកកំពស់ការយល់ដឹងពីបញ្ហាគ្រឿងញៀនដល់សហគមន៍នានា ដើម្បីរួមចំណែកក្នុងការជួយទប់ស្កាត់ការប្រើបំពានគ្រឿងញៀន ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត។

៤. ជំរុញឱ្យមានការរៀបចំបង្កើតមជ្ឈមណ្ឌលព្យាបាល និងស្តារ នីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

៥. ជំរុញការអនុវត្តន៍កម្មវិធីសមាហរណកម្មអ្នកញៀនគ្រឿងញៀនទៅក្នុងសង្គមជាតិវិញ ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៦. អនុវត្តកិច្ចសហប្រតិបត្តិការ និងអន្តរាគមន៍គាំទ្រដល់សកម្មភាពអនុវត្តច្បាប់របស់ភ្នាក់ងារអនុវត្តច្បាប់ដទៃទៀត ស្របតាមនីតិវិធី ។

៧. តាក់តែងសេចក្តីព្រាងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងបទប្បញ្ញត្តិ ក្នុងវិស័យបង្ការនិងបង្ក្រាបការដាំដុះ ការផលិត ការជួញដូរគ្រឿងញៀន ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។

៨. តាមដានការវិវត្តន៍នីតិក្រមរបស់រដ្ឋ និងលើកសំណើធ្វើវិសោធនកម្មច្បាប់ កែសំរួលព្រះរាជក្រឹត្យ អនុក្រឹត្យ និងបទប្បញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធនឹងគ្រឿងញៀន ក្នុងន័យធ្វើអោយដំណើរការនៃការត្រួតពិនិត្យគ្រឿងញៀនកាន់តែមានប្រសិទ្ធភាព។

នាយកដ្ឋាន នីតិកម្ម អប់រំ និងស្តារនីតិសម្បទា ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានជាជំនួយការ ។

មាត្រា ១២ :- នាយកដ្ឋានស្រាវជ្រាវ និងត្រួតពិនិត្យ មានភារកិច្ចដូចតទៅ ÷

១. ស្រាវជ្រាវ ក្តាប់សភាពការណ៍ ប្រមូលពតិមានទូទៅដែលពាក់ព័ន្ធនឹងសារធាតុគីមី និងសារធាតុទាំងឡាយដែលប្រើប្រាស់សំរាប់ផ្សំគ្រឿងញៀន · ព្រមទាំងសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃ

ប្រសាទ និងឱសថដែលមានសារធាតុញៀន សំដៅលើកវិធានការគ្រប់គ្រង ត្រួតពិនិត្យ និងទប់ស្កាត់ឱ្យមានប្រសិទ្ធភាព ។

២. សហការ និងចូលរួមក្នុងកិច្ចប្រតិបត្តិការជាមួយក្រសួង និងអង្គភាពពាក់ព័ន្ធដទៃទៀត ក្នុងការតាមដាន និងត្រួតពិនិត្យ សារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និងសារធាតុគីមីសំរាប់ផលិតគ្រឿងញៀន និងឱសថដែលមានសារធាតុញៀន និងថ្នាំញៀនស្របច្បាប់ កំណត់ដោយក្រសួងសុខាភិបាល ។

៣. សហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការត្រួតពិនិត្យ តាមដាន និងទប់ស្កាត់ការនាំចេញ នាំចូល ការចរាចរ ការប្រើប្រាស់ ការផលិត ការស្តុកទុកនូវសារធាតុគីមីផ្សំគ្រឿងញៀន និងសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ។

៤. សហការក្នុងការទប់ស្កាត់ការបង្វែរសារធាតុគីមីផ្សំ ពីជំនួញស្របច្បាប់ ទៅបំរើគោលដៅផលិតគ្រឿងញៀនខុសច្បាប់ ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអង្គការដទៃទៀត ។

នាយកដ្ឋានស្រាវជ្រាវ និងត្រួតពិនិត្យត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានជាជំនួយការ ។

ជំពូក ៤
មន្ទីរពិសោធន៍គ្រឿងញៀន

មាត្រា ១៣ :-

មន្ទីរពិសោធន៍គ្រឿងញៀន មានភារកិច្ចដូចតទៅ :

១. ធ្វើវិភាគ ស្រាវជ្រាវ តាមបែបវិទ្យាសាស្ត្រ លើលក្ខណៈគីមី និងលក្ខណៈរូបនៃសារធាតុគ្រឿងញៀន និង គីមីផ្សំ គ្រឿងញៀនដែលបានកំណត់ក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា នៅក្នុងរុក្ខជាតិ សារធាតុគីមី វត្ថុធាតុដែលមាននៅក្នុងសរីរាង្គមនុស្ស ចំណីអាហារ ភេសជ្ជៈ និង ឱសថបុរាណ/សម័យ ។

២. ធ្វើការវិភាគរកគុណភាព បរិមាណសារធាតុញៀន និងគីមីផ្សំគ្រឿងញៀនដែលក្រសួង-ស្ថាប័នមានសមត្ថកិច្ចប្រគល់ជូន និងផ្តល់ជូននូវលទ្ធផលនៃការវិភាគទាំងនេះវិញ ។

៣. ធ្វើការផលិតសារធាតុប្រតិករសំរាប់ធ្វើតេស្តពណ៌ជំហានដំបូងលើសារធាតុញៀន និងសារធាតុគីមីផ្សំគ្រឿងញៀន ។

៤. ធ្វើការសិក្សាស្រាវជ្រាវរកសារធាតុញៀន ឬ សារធាតុគីមីផ្សំគ្រឿងញៀនថ្មី ឬ សារធាតុពុលផ្សេងទៀត ដែលនាំឱ្យប៉ះពាល់ដល់សុខភាព ដើម្បីដាក់ចូលទៅក្នុងតារាងត្រួតពិនិត្យសារធាតុគ្រឿងញៀននៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយសហការជាមួយក្រសួងសុខាភិបាល និងមន្ទីរពិសោធន៍ ផ្សេងៗទៀតដែលពាក់ព័ន្ធ ។

៥. ធ្វើការរក្សាទុក វិភាគ និង ប្រៀបធៀបទិន្នន័យ ស្តីពីលក្ខណៈរូប លក្ខណៈគីមី ដើម្បីរកពត៌មានចាំបាច់ដែលពាក់ព័ន្ធសំរាប់បំរើការងារស៊ើបអង្កេត ។

៦. លើកសំណើជូនអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្តីពីការផលិត និងការធ្វើជំនួញឱសថសម័យ ឱសថបុរាណ ភេសជ្ជៈ គ្រឿងស្រវឹង គ្រឿងបរិភោគនៅក្នុងប្រទេស និងថ្នាំស្របច្បាប់កំណត់ដោយក្រសួងសុខាភិបាល ដែលមន្ទីរពិសោធន៍គ្រឿងញៀនស្រាវជ្រាវរកឃើញថា មានសារធាតុគ្រឿងញៀនលើសកំរិតសុវត្ថិភាព ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាព និងសុវត្ថិភាពសង្គម ដើម្បីធ្វើការហាមឃាត់ ។

មន្ទីរពិសោធន៍គ្រឿងញៀនត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធានមន្ទីរពិសោធន៍មួយរូប និងមានអនុប្រធានជាជំនួយការ ។

ជំពូក ៥
អវសានប្បញ្ញត្តិ

មាត្រា ១៤ :-

រាល់អនុក្រឹត្យ និងសេចក្តីសំរេចពីមុនដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៥ :-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពដែលពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ១៦ :-

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីទៅជំរាបជូន សម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ស ខេង

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៥
- ឯកសារ-កាលប្បវត្តិ

រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន
នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៦៧. អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនលោកសាស្ត្រាចារ្យ **អ៊ីន សាម្ល** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យអន្តរជាតិ ដែលមានស្នាដៃល្អ ក្នុងការចូលរួមកសាង និងអភិវឌ្ឍន៍ធនធានមនុស្ស នៅព្រះរាជាណាចក្រកម្ពុជា ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៨.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យអន្តរជាតិ ចំនួន១៨រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមចំណែកជួយកសាង និងអភិវឌ្ឍន៍ធនធានមនុស្ស ដូចមានរាយនាមខាងក្រោម :-

១-លោកជំទាវ បណ្ឌិត **ខួន ធីតា**
២-ឯកឧត្តម បណ្ឌិត **ហ៊ុខ ម៉ូរ៉ាក់ស៊ី**
៣-ឯកឧត្តម ឱសថបណ្ឌិត **ចំរើន ប៊ុនពិជ**
៤-លោកសាស្ត្រាចារ្យ វេជ្ជ. **ខេង សឿន**
៥-លោកសាស្ត្រាចារ្យ **ហេង ស៊ុន**
៦-លោកវេជ្ជ.ឯកទេស **ជុំ សុខហ៊ាន**
៧-លោកបណ្ឌិត **សរ ម៉ូរ៉ាន់**
៨-លោកសាស្ត្រាចារ្យ វេជ្ជ. **ឈិន សែនយ៉ា**
៩-លោកឱសថបណ្ឌិត **ឈាង សេនា**
១០-លោកស្រី វេជ្ជ.ឯកទេស **ធីញ ផាណាចារិន**

១១-លោកស្រីសាស្ត្រាចារ្យ វេជ្ជ. ស្រី សុផា
១២-លោកទន្តបណ្ឌិត និត ហុងយី
១៣-លោកវេជ្ជ.ឯកទេស ម៉ុក នាទី
១៤-លោក បណ្ឌិត យ៉េង សាំងកុម៉ារ
១៥-លោក អនុបណ្ឌិត ចាន់ ទុត្តា

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ X+

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តតាកែវ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនមន្ត្រីជាន់ខ្ពស់ ចំនួន ០២រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ក្នុងការជួយកសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈផ្សេងៗ និង ជួយកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋ នៅឃុំកំណប់ ស្រុកគីរីវង់ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តមបណ្ឌិត **អ៊ឹម ឆុន**	សាកលវិទ្យាធិការ នៃ សាកលវិទ្យាល័យជាតិគ្រប់គ្រង
២-ឯកឧត្តមបណ្ឌិត **តេង្គ ឥរិយា**	សមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តតាកែវ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនសប្បុរសជន មន្ត្រី រាជការ ចំនួន១៦រូប ដែលមានស្នាដៃល្អបានខិតខំបរិច្ចាគកម្លាំងកាយ-ចិត្ត និងធនធានជួយកសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈផ្សេងៗ ព្រមទាំងជួយកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋ នៅឃុំកំណប់ ស្រុកគីរីវង់ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :-

១-លោក	**គឹក គុនឈឹម**	អភិបាលស្រុកគីរីវង់ ខេត្តតាកែវ
២-លោក	**យូ ប៊ុនឡេង**	ចៅក្រមតុលាការឧទ្ធរណ៍
៣-បណ្ឌិត	**នេព សូវ៉ាន**	ព្រឹទ្ធបុរសមហាវិទ្យាល័យ សេដ្ឋកិច្ច នៃសាកលវិទ្យាល័យសេដ្ឋកិច្ច និងនីតិសាស្ត្រ
៤-លោក	**ឯក ប៊ូឈីន**	ប្រធាននាយកដ្ឋាន ហិរញ្ញកិច្ច ស៊ីម៉ាក់
៥-លោក	**ឌី ប៊ូរ៉ា**	មេធាវី
៦-លោក	**យ៉ា សុខន**	ចៅក្រមអង្គជំនុំជម្រះវិសាមញ្ញ តុលាការកម្ពុជា
៧-លោក	**ឃើន ចរិយា**	ព្រះរាជអាជ្ញារងអមអង្គជំនុំជម្រះវិសាមញ្ញ តុលាការកម្ពុជា
៨-លោក	**ម៉េង អុល**	ចៅក្រមតុលាការ ខេត្តកំពង់ចាម
៩-បណ្ឌិត	**ឈុន ពាឃុ**	សាស្ត្រាចារ្យ សាកលវិទ្យាល័យសេដ្ឋកិច្ច និង នីតិសាស្ត្រ

១០-បណ្ឌិត	ហោ ប៉េង	សាស្ត្រាចារ្យ សាកលវិទ្យាល័យសេដ្ឋកិច្ច និង នីតិសាស្ត្រ
១១-បណ្ឌិត	ចាន់ សាវរី	ព្រឹទ្ធបុរសមហាវិទ្យាល័យកុំព្យូទ័រ នៃសាកលវិទ្យាល័យសេដ្ឋកិច្ច និង នីតិសាស្ត្រ
១២-លោក	គុ ពៅស៊ុន	ចៅក្រមតុលាការ ក្រុងភ្នំពេញ
១៣-លោក	ស៊ូ ផល្លា	ព្រឹទ្ធបុរសមហាវិទ្យាល័យគ្រប់គ្រង នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង
១៤-លោក	ម៉េង សុខុម	ប្រធានការិយាល័យអភិវឌ្ឍន៍ជនបទ ស្រុកគិរីវង់
១៥-លោក	សុខ ឈាង	ចៅក្រមតុលាការ ខេត្តតាកែវ
១៦-លោក	ចក់ គឹមឃឿង	ប្រធានក្រុមប្រឹក្សា ឃុំកំណប់ ស្រុកគិរីវង់ ខេត្តតាកែវ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:..១៣៧១...អនក្រ..បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
៣៧
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ និងជូនសប្បុរសជន ចំនួន ១៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងវត្តប្រជុំទី ហៅ វត្តក្រពើហា ឃុំព្រែកឫស្សី ស្រុកតាខ្មៅ ខេត្តកណ្តាល ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក.មេដាយមាសស្ថាបនាជាតិ :

១-ព្រះវិន័យមុនី **ញ៉ៀម សុគន្ធ** រាជាគណៈថ្នាក់ចត្វា និង ជាចៅអធិការ វត្តប្រជុំទី បច្ច័យចំនួន ២០.០០០ ដុល្លារ

២-ព្រះតេជគុណ **ចាម ហ៊ុយ** គ្រូសូត្រឆ្វេង វត្តប្រជុំទី បច្ច័យចំនួន ១០.០០០ ដុល្លារ

៣-លោក **ពេជ្រ សារឿន** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១២.០០០ ដុល្លារ

៤-ឧបាសក **គិន ឡាង** សប្បុរសជនខ្មែររស់នៅប្រទេសបារាំង ថវិកាចំនួន ១១.៥០០ ដុល្លារ

៥-ឧបាសិកា **ម៉ម ឯម** សប្បុរសជនខ្មែររស់នៅប្រទេសស្វីស ថវិកាចំនួន ១០.១៥០ ដុល្លារ

៦-លោកជំទាវ **លី ស៊ុណា** ភរិយាឯកឧត្តម **គីម ប៊ុនថាន** ថវិកាចំនួន ១០.០០០ ដុល្លារ

៧-ឧបាសិកា **អ៊ុំ គីមឃួន** សប្បុរសជនខ្មែររស់នៅប្រទេសបារាំង ថវិកាចំនួន ១០.០០០ ដុល្លារ

៨-ឧបាសិកា **មាស ស៊ីវន** សប្បុរសជនខ្មែររស់នៅប្រទេសបារាំង ថវិកាចំនួន ១០.០០០ ដុល្លារ

៩-លោកស្រី **ជា សុខធាន** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១០.០០០ ដុល្លារ

ខ_មេដាយគ្រាក់ស្ហាបនាជាតិ :

១-ឧបាសិកា	**អ៊ឹម**	**យ៉េន**	សប្បុរសជននៅខេត្តកណ្តាល	ថវិកាចំនួន	៩.០០០ ដុល្លារ
២-លោកជំទាវ	**សុខ**	**តារាយ៉ាន្នី**	ភរិយាឧកញ៉ា ជុំ **សារឿន**	ថវិកាចំនួន	៨.៥០០ ដុល្លារ
៣-លោកស្រី	**នៃ**	**ឈីន**	សប្បុរសជននៅខេត្តកណ្តាល	ថវិកាចំនួន	៨.០០០ ដុល្លារ
៤-ឧបាសិកា	**សាំង**	**ស៊ីនួន**	សប្បុរសជនខ្មែររស់នៅប្រទេសស្វីស	ថវិកាចំនួន	៧.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧២ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙៚

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តតាកែវ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះតេជគុណ **ឡុង ពុទ្ធិសំភ** គង់នៅវត្តព្រះធាតុ ឃុំរលួស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលបានបរិច្ចាគបច្ច័យផ្ទាល់ព្រះអង្គ ចំនួន ១៣.១០០ ដុល្លារអាមេរិក ជួយកសាងព្រះវិហារ វត្តថ្នឹកជ្រៃ ក្នុងឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣៧

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ និងជូនសប្បុរសជន ចំនួន០៩រូប ដែលបានបរិច្ចាគធនធាន ជួយកសាងសមិទ្ធផលផ្សេងៗ នៅវត្តជលធារាសម្បត្តិទួលក្រសាំង ក្នុងឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក.មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ	**ឃោម**	**សុវណ្ណារិទ្ធិ**	ចៅអធិការវត្តជលធារាសម្បត្តិទួលក្រសាំង	បច្ច័យចំនួន ១៥.០០០ ដុល្លារ
២-លោក	**សារុទ**	**ម៉ុនឃោម**	នៅក្រុងភ្នំពេញ	ថវិកាចំនួន ១៦.០០០ ដុល្លារ
៣-លោក	**ភាំង**	**ឈាងចំណន្ទ**	នៅក្រុងភ្នំពេញ	ថវិកាចំនួន ១៤.៥០០ ដុល្លារ
៤-លោក	**សេក**	**ឆាក់**	ប្រធានគណៈកម្មការវត្ត	ថវិកាចំនួន ១២.០០០ ដុល្លារ

ខ.មេដាយប្រាក់ស្ថាបនាជាតិ :

១-លោក	**ស្តើង**	**សរ**	អនុប្រធានគណៈកម្មការវត្ត	ថវិកាចំនួន ៨.២០០ ដុល្លារ
២-លោក	**ជ្រឹន**	**សឿន**	អនុប្រធានគណៈកម្មការវត្ត	ថវិកាចំនួន ៧.៥០០ ដុល្លារ
៣-លោក	**ចាន**	**ជឿន**	អនុប្រធានគណៈកម្មការវត្ត	ថវិកាចំនួន ៧.៥០០ ដុល្លារ

គ.មេដាយសំរិទ្ធស្ថាបនាជាតិ :

១-លោក	**ឈុយ**	**នួន**	អាចារ្យវត្តទួលក្រសាំង	ថវិកាចំនួន ៤.៣៥០ ដុល្លារ
២-លោក	**គង់**	**ឃុល**	អាចារ្យវត្តទួលក្រសាំង	ថវិកាចំនួន ៤.១២០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ១៧៤.អនក្រ.តត

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

សម្រេច

មាត្រា១ ៈ ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីអង្គការអន្តរជាតិនានា និងមន្ត្រីនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ចំនួន២២រូប ដែលមានស្នាដៃល្អក្នុងការចូលរួមការងារគ្រប់គ្រងគ្រោះមហន្តរាយ និងជួយសង្គ្រោះប្រជាពលរដ្ឋរងគ្រោះ កន្លងមក ដូចមានរាយនាមខាងក្រោមនេះ :-

ក_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១-លោក	Thomas Keusters	WFP
២-លោក	Douglas Gardner	UNDP
៣-លោក	Sharon Wilkinson	Care
៤-លោក	Michael O'Leary	WHO
៥-លោក	Francis Perez	Oxfam

ខ_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

១-លោក	ឃុន សុខា	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
២-លោក	រស់ សុវណ្ណ	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
៣-លោក	ឈាង ណារ៉ាក់	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
៤-លោក	ជួប ស៊ីថន	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
៥-លោក	នាង ទំនែន	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
៦-លោក	ឃួន យ៉ា	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
៧-លោក	ពៅ សុនារា	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
៨-លោក	កែម ទី	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
៩-លោក	អ៊ូ ចាន់ឌី	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

១០-លោក **ឃឿន ខូន** គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
១១-លោក **ញឹក ប៊ុនឆៃ** គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
១២-លោក **ចយ ភារា** គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
១៣-លោកស្រី **ម៉ឺន មណ្ណធី** គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

គ_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :

១-លោក **ម៉ែន សំអន** គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
២-លោក **តៅ គឹរ៉ា** គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
៣-លោក **ខៀវ ចំនួមុនី** គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
៤-លោក **អ៊ឹម សុផល** គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ខែ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧៤៥ ... អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ
៙
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

សម្រេច

មាត្រា១ : ត្រូវបានចំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ ចំនួន១៤រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោមនេះ :-

១-លោក	**មាស ឃីត**	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
២-លោក	**អែម ហួន**	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
៣-លោក	**គួណ ធីរៈ**	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
៤-លោក	**កែវ សុវណ្ណារី**	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
៥-លោក	**ខៀវ សុខ្ន**	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
៦-លោក	**ជា ប្រុណិត**	ទីស្តីការគណៈរដ្ឋមន្ត្រី
៧-លោក	**សុខ គីមកុលមុន្នី**	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
៨-លោក	**ម៉ៅ សៅឃាន**	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
៩-លោកស្រី	**មាស សំអឺល**	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
១០-លោក	**គីម សារម៉ត**	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
១១-លោក	**ពេជ រចនា**	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
១២-លោក	**អោម អ៊ិន**	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
១៣-លោក	**រ៉ែ ចួន**	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
១៤-លោក	**ខាង ឌិត**	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ... ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០៤...សសរ

សេចក្តីសំរេច

ស្តីពី

ការរៀបចំ «វេទិកាសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១»

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ខែកក្កដាឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៤៧អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមិនា ឆ្នាំ២០០៦ ស្តីពីការកែសំរួលមាត្រា១ នៃអនុក្រឹត្យលេខ១៤៧ អនក្រ.បក
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សំរេច

ប្រការ ១ :-

ប្រគល់ភារកិច្ចជូនឯកឧត្តម គាត ឈន់ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការដឹកនាំ និងសំរបសំរួលការត្រៀមរៀបចំសំរាប់ **«វេទិកាសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១»** នាខែមិថុនាឆ្នាំ២០០៧ ខាងមុខនេះ ។

ប្រការ ២ :-

ក្នុងក្របខ័ណ្ឌនៃការដឹកនាំនិងសំរបសំរួលការត្រៀមរៀបចំសំរាប់វេទិកាលើកទី១នេះ ឯកឧត្តម **គាត ឈន់** ត្រូវសហការជាមួយប្រធាននៃបណ្តាក្រសួងនិងស្ថាប័នទាំងអស់នៃរាជរដ្ឋាភិបាល និងមានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់ ឱ្យចូលរួមប្រជុំអន្តរក្រសួង និងមានសិទ្ធិចាត់តាំងពិគ្រោះយោបល់ជាមួយនឹងបណ្តាដៃគូអភិវឌ្ឍន៍ទាំងអស់ ដើម្បីសំរបសំរួលការងារ និងដើម្បីរៀបចំសេចក្តីព្រាងឯកសារចាំបាច់នានា ។

ប្រការ ៣ :-

ឯកឧត្តម **គាត ឈន់** ត្រូវរាយការណ៍ជាបន្តបន្ទាប់ជូនសម្តេចនាយករដ្ឋមន្ត្រី អំពីវឌ្ឍនភាពនៃការរៀបចំវេទិកាលើកទី១ និងឯកសារចាំបាច់នានា ដើម្បីដាក់ជូនសម្តេចនាយករដ្ឋមន្ត្រីពិនិត្យ ផ្តល់អនុសាសន៍ និងអនុម័ត មុននឹងយកទៅប្រើប្រាស់ជាផ្លូវការ ។

ប្រការ ៤ :-

ក្នុងការបំពេញភារកិច្ចនេះ ឯកឧត្តម **គាត ឈន់** ប្រើប្រាស់រចនាសម្ព័ន្ធរបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (ក.អ.ក/គ.ជ.នា) ដែលមានឯកឧត្តម **ឈឿន យ៉ាណារ៉ា** ជាអគ្គលេខាធិការ សំរាប់ជំនួយការងារប្រចាំថ្ងៃ ។

ប្រការ ៥ :-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម **គាត ឈន់** ត្រូវអនុវត្តតាមសេចក្តីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ៦ :-

សេចក្តីសំរេចនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខារហូតដល់វេទិកាសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១បានប្រព្រឹត្តទៅចប់សព្វគ្រប់ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេច នាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:.......០៩...សសរ

សេចក្តីសម្រេច

ស្តីពី

«ឯកសារណែនាំសំរាប់ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមការងារបច្ចេកទេសចំរុះ»

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ខែកក្កដាឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
